# ឥណទានពលរដ្ឋរុងរឿង អិលធីឌី

របាយការណ៍ហិរញ្ញវត្ថុ
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់
ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019
និង
របាយការណ៍របស់សវនករឯករាជ្យ

# ព័ត៌មានអំពីក្រុមហ៊ុន

| | | |
|---|---|---|
| ក្រុមហ៊ុន | **ឥណទានពលរដ្ឋរុងរឿង អិលធីឌី** | |
| ចុះបញ្ជីពាណិជ្ជកម្មលេខ | 00017643 | |
| ទីស្នាក់ការចុះបញ្ជី | អគារ 779A ផ្លូវ កម្ពុជាក្រោម (128)<br>សង្កាត់ ទឹកល្អក់ I ខណ្ឌ ទួលគោក<br>រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| ភាគទុនិក | ឧកញ៉ា ភូ ពុយ | |
| ក្រុមប្រឹក្សាភិបាល | ឧកញ៉ា ភូ ពុយ | ប្រធានក្រុមប្រឹក្សាភិបាល |
| | លោក Hsu Ming Yee | អភិបាលឯករាជ្យ |
| | លោកស្រី ប៉ុក នីរីល័យ | អភិបាលឯករាជ្យ |
| អ្នកគ្រប់គ្រង | លោក ហ៊ត ប៊ុនសុង | នាយកប្រតិបត្តិ |
| | លោក ហៃ គឹមយន | នាយកហិរញ្ញវត្ថុនិងរដ្ឋបាល |
| | លោក ចេង វណ្ណេត | នាយកប្រតិបត្តិការ |
| | លោក កាសៀប កាសាជូវ៉ា | នាយកសវនកម្មផ្ទៃក្នុង |
| ធនាគារិកចម្បង | ធនាគារ អេស៊ីលីដា ភីអិលស៊ី | |
| សវនករ | ខេភីអឹមជី ខេមបូឌា ចំកាត់ | |

**ឥណទានពលរដ្ឋខុខឿង អិលធីឌី**

## មាតិកា

ទំព័រ


| | | |
|---|---|---|
| 1. | របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | 1 |
| 2. | របាយការណ៍របស់សវនករឯករាជ្យ | 6 |
| 3. | របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | 10 |
| 4. | របាយការណ៍លទ្ធផលលម្អិត | 11 |
| 5. | របាយការណ៍ស្តីពីបម្រែបម្រួលមូលធន | 12 |
| 6. | របាយការណ៍លំហូរទឹកប្រាក់ | 13 |
| 7. | កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ | 15 |

ឥណទានពលរដ្ឋរុងរឿង អិលធីឌី
INTEAN POALROATH RONGROEURNG LTD

Address: # 779A, Kampuchea Kraom Blvd, Sangkat Tuek Laak 1, Khan Tuol Kouk, Phnom Penh, Cambodia.
Phone: 023 990 237, Fax: 023 950 211, Email: info@iprmfi.com, Website: www.iprmfi.com

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល មានសេចក្តីសោមនស្សរីករាយ ធ្វើការបង្ហាញនូវរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរបស់ **ឥណទានពលរដ្ឋរុងរឿង អិលធីឌី** ហៅកាត់ថា ("ក្រុមហ៊ុន") ដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 ។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុ។ សេវាកម្មទាំងនោះ រួមមានការផ្តល់ជូនឥណទានសម្រាប់សហគ្រាសធុនតូច និងគ្រួសារ ដែលមានប្រាក់ចំណូលទាបនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានដូចខាងក្រោមៈ

| | 2019<br>ដុល្លារអាមេរិក | 2018<br>ដុល្លារអាមេរិក | 2019<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) | 2018<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | 393,549 | 232,589 | 1,594,661 | 940,823 |
| ចំណាយពន្ធលើប្រាក់ចំណេញ | (81,673) | (70,235) | (330,939) | (284,101) |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | 311,876 | 162,354 | 1,263,722 | 656,722 |

## ដើមទុន

មិនមានការផ្លាស់ប្តូរដើមទុនដែលបានចុះបញ្ជី និង បានបង់របស់ក្រុមហ៊ុនក្នុងកំឡុងការិយបរិច្ឆេទនោះទេ ។

## ភាគលាភ

ពុំមានការប្រកាស ឬការបែងចែកភាគលាភទេ ហើយអភិបាលមិនបានស្នើឲ្យមានការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទនេះទេ ។

# ឥណទានពលរដ្ឋរុងរឿង អិលធីឌី

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តនៃទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## ឥណទានអាក្រក់ និងជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការលុបបំបាត់ចោលឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលមានការជឿជាក់ថា រាល់ឥណទានដែលបានដឹងថា មិនអាចទារបានត្រូវបានលុបបំបាត់ចោល ហើយសំវិធានធនគ្រប់គ្រាន់ត្រូវបានកំណត់ឡើងសម្រាប់ឥណទានអាក្រក់ និងជាប់សង្ស័យ ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងបណ្តាលឲ្យចំនួននៃការលុបបំបាត់ចោលឥណទានអាក្រក់ ឬ ចំនួននៃការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ មានលក្ខណៈមិនគ្រប់គ្រាន់រហូតដល់កម្រិតជាសារវន្តណាមួយនោះទេ ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា បណ្តាទ្រព្យសកម្មចរន្ត លើកលែងបំណុល ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ហើយដែលសន្និដ្ឋានថា មានតម្លៃមិនអាចប្រមូលមកវិញបាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចប្រមូលបានជាក់ស្តែង ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្ត នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវនោះទេ ។

## វិធីសាស្ត្រកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ ។

## ឥណទានពលរដ្ឋរុងរឿង អិលធីឌី

### បំណុលយថាភាព និងបំណុលផ្សេងៗទៀត

នាថ្ងៃចេញរបាយការណ៍នេះ ពុំមាន៖

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមក ក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមមហ៊ុន ។

ក្រុមប្រឹក្សាភិបាលយល់ឃើញថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុន ដែលក្រុមហ៊ុនត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងអំឡុងពេលដប់ពីរខែ បន្ទាប់ពីថ្ងៃបញ្ចប់ការិយបរិច្ឆេទ នឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលដែលដល់ថ្ងៃកំណត់ឡើយ ។

### ប្រតិបត្តិការមិនប្រក្រតី

តាមមតិរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬ ព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈមិនប្រក្រតីនោះទេ ។

ក្រុមប្រឹក្សាភិបាល ក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើង ដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ ។

### ព្រឹត្តិការណ៍ចាប់តាំងពីកាលបរិច្ឆេទនៃរបាយការណ៍

នាថ្ងៃចេញរបាយការណ៍នេះ លើកលែងតែការបង្ហាញនៅក្នុងកំណត់សម្គាល់ 28 ពុំមានហេតុការណ៍ណាមួយដែលនឹងបណ្តាលឲ្យមានតួលេខនៃចំនួនណាមួយ ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ ។

### ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលបានបម្រើការក្នុងអំឡុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះរួមមាន៖

| | |
|---|---|
| ឧកញ៉ា ភួ ពុយ | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក Hsu Ming Yee | អភិបាលឯករាជ្យ |
| លោកស្រី ប៉ុក នីរីល័យ | អភិបាលឯករាជ្យ |

# ធនាគារពលរដ្ឋរុខរឿខ អិលធីឌី

## ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលដែលបានបម្រើការងាររហូតដល់ចុងការិយបរិច្ឆេទ និងចំណែកហ៊ុនដែលមាននៅក្នុងក្រុមហ៊ុន ត្រូវបានបង្ហាញដូចខាងក្រោម៖

| | 2019 | | 2018 | |
|---|---|---|---|---|
| | % កាន់កាប់ | ចំនួន ភាគហ៊ុន | % កាន់កាប់ | ចំនួន ភាគហ៊ុន |
| ឧកញ៉ា ភួ ពុយ | | | | |
| 25,955 ភាគហ៊ុនដែលមានតម្លៃចារឹក 119 ដុល្លារអាមេរិកក្នុង 1ភាគហ៊ុន | 100% | 25,955 | 100% | 25,955 |

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ គឺមិនមានកិច្ចព្រមព្រៀងណាមួយដែលក្រុមហ៊ុនជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះអាចផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាភិបាលណាម្នាក់ឲ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬសាជីវកម្មដទៃ ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមុន ពុំមានក្រុមប្រឹក្សាភិបាលណាម្នាក់របស់ក្រុមហ៊ុនបានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានរួមបញ្ចូលនៅក្នុងបរិលាភសរុប ទទួលបាន ឬដល់កំណត់ទទួលបានដោយក្រុមប្រឹក្សាភិបាល ដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬដោយក្រុមហ៊ុនពាក់ព័ន្ធជាមួយនឹងក្រុមហ៊ុន ដែលក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុន ដែលក្រុមប្រឹក្សាភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

(ក) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព ។

# ឥណទានពលរដ្ឋរុងរឿង អិលធីឌី

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ (ត)

(ខ) អនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះ ដើម្បីបង្ហាញនូវភាពពិត និងត្រឹមត្រូវ គឺត្រូវតែបង្ហាញពន្យល់ និងកំណត់បរិមាណឲ្យបានច្បាស់លាស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

(គ) ត្រួតពិនិត្យប្រព័ន្ធដំណើរការរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព ។

(ឃ) វាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធ នូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ និង

(ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធភាព លើរាល់សេចក្តីសម្រេចដែលមានសារៈសំខាន់ទាំងឡាយ ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា ក្រុមប្រឹក្សាភិបាលបានអនុវត្តនូវរាល់តម្រូវការ ដូចមានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ដែលបានបង្ហាញនៅទំព័រទី10 ដល់ទី 53 ដែលជាមតិរបស់យើងខ្ញុំ បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម។

*ហត្ថលេខាជំនួសឲ្យក្រុមប្រឹក្សាភិបាល*

INTEAN POALROATH RONGROEURNG LTD.

**ឧកញ៉ា ភូ ពុយ**

*ប្រធានក្រុមប្រឹក្សាភិបាល*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី៖ 29 MAY 2020

KPMG

KPMG Cambodia Ltd
4th Floor, Delano Center
No. 144, Street 169, Sangkat Veal Vong
Khan 7 Makara, Phnom Penh
Kingdom of Cambodia
+855 23 216 899 | kpmg.com.kh

# របាយការណ៍របស់សវនករឯករាជ្យ
## ជូនចំពោះភាគទុនិករបស់
## ឥណទានពលរដ្ឋរុងរឿង អិលធីឌី

### *មតិសវនកម្ម*

យើងខ្ញុំ បានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ **ឥណទានពលរដ្ឋរុងរឿង អិលធីឌី** ហៅកាត់ថា ("ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 របាយការណ៍លទ្ធផលលម្អិត របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់និងកំណត់សម្គាល់ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗ ដែលបានបង្ហាញនៅទំព័រទី 10 ដល់ទី 53 (ដែលហៅកាត់ថា "របាយការណ៍ហិរញ្ញវត្ថុ") ។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុជាសារវន្ត បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធនតូច និងមធ្យម ។

### *មូលដ្ឋាននៃមតិសវនកម្ម*

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ។ ការទទួលខុសត្រូវរបស់យើងខ្ញុំ ដែលស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពី *ការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ* ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ ។ យើងខ្ញុំ មានភាពឯករាជ្យពីក្រុមហ៊ុនដោយស្របទៅតាមតម្រូវការក្រមសីលធម៌វិជ្ជាជីវៈ ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវលើក្រមសីលធម៌វិជ្ជាជីវៈ ស្របតាមតម្រូវការរបស់ស្តង់ដារទាំងនោះ ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំ ប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។

KPMG Cambodia Ltd, a Cambodian limited liability company and a member firm of the KPMG network of independent member firms affiliated with KPMG International Cooperative ("KPMG International"), a Swiss entity.
Document classification: KPMG Confidential.

KPMG

### *បញ្ហាផ្សេងៗ*

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 និងការិយបរិច្ឆេទដែលបានបញ្ចប់ ដែលបានរៀបចំឡើងអនុលោមតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ គឺត្រូវបានធ្វើសវនកម្មដោយសវនករផ្សេង ដោយបានបញ្ចេញមតិនៅថ្ងៃទី 30 ខែ មេសា ឆ្នាំ 2019 ថារបាយការណ៍នោះមានភាពត្រឹមត្រូវ ។

ដូចបានបង្ហាញនៅក្នុងកំណត់សម្គាល់ 27 នៃរបាយការណ៍ហិរញ្ញវត្ថុ ក្រុមហ៊ុនបានអនុវត្តតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យមនាថ្ងៃទី 1 ខែ មករា ឆ្នាំ 2019 ដែលមានកាលបរិច្ឆេទអន្តរកាលនៅថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ។ ស្តង់ដារទាំងនេះ គឺត្រូវអនុវត្តតាមវិធីសាស្ត្រប្រតិសកម្មលើព័ត៌មានប្រៀបធៀបនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 និងថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 ព្រមទាំងរបាយការណ៍លទ្ធផលលម្អិត របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 និងកំណត់ពន្យល់ពាក់ព័ន្ធផ្សេងៗ ។

យើងខ្ញុំ មិនតម្រូវឲ្យធ្វើសវនកម្មលើព័ត៌មានប្រៀបធៀបដែលបានកែប្រែឡើងវិញឡើយហើយព័ត៌មានទាំងនេះមិនត្រូវបានធ្វើសវនកម្មទេ ។ ការទទួលខុសត្រូវរបស់យើងខ្ញុំ លើព័ត៌មានប្រៀបធៀបទាំងនេះ គឺត្រូវ កំណត់ថាតើរបាយការណ៍ហិរញ្ញវត្ថុ បានរួមបញ្ចូលនូវព័ត៌មានប្រៀបធៀបដែលតម្រូវដោយស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម និងថាតើព័ត៌មានប្រៀបធៀបទាំងនេះត្រូវបានធ្វើចំណាត់ថ្នាក់សមស្រប ឬទេ ។

### *ព័ត៌មានផ្សេងៗ*

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ ។ ព័ត៌មានផ្សេងៗរួមបញ្ចូលនូវពត័មានដែលមាននៅក្នុងរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលដែលបានបង្ហាញនៅទំព័រទី 1 ដល់ទី 5 ។ មតិសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំ មិនធ្វើការផ្តល់នូវអំណះអំណាងណាមួយទៅលើព័ត៌មាននេះទេ ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំគឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុងឆ្គងជាសារវន្ត ។ ប្រសិនបើការអានព័ត៌មានផ្សេងៗ អាចឲ្យយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មាន ផ្សេងៗ នេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង ។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹង ព័ត៌មានផ្សេងៗ នេះទេ ។

KPMG

## *ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច*

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម ហើយនិងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជីផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ។

## *ការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ*

គោលដៅរបស់យើងខ្ញុំ គឺផ្តល់នូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលមតិសវនកម្មរបស់យើងខ្ញុំ ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែ វាមិនអាចធានាថា គ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជាអាចរកឃើញនូវកាបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ ។ កាបង្ហាញខុសជាសារវន្តអាចកើតឡើងដោយសារ ការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នា មានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំ អនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយម ក្នុងអំឡុងពេលសវនកម្ម ។ យើងខ្ញុំក៏៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុ ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប សម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលកើតឡើង ដោយសារតែការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំ អាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង ។
- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីរៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ ។

- វាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យ ដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង ។
- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃ ការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់ជាសារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ក្រុមហ៊ុនដើម្បីបន្តនិរន្តរភាពអាជីវកម្ម ។ ប្រសិនបើយើងខ្ញុំ ធ្វើការសន្និដ្ឋានថាមានអស្ថិរភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ។ យ៉ាងណាក៏ដោយព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគត អាចធ្វើឲ្យក្រុមហ៊ុនបញ្ឈប់និរន្តរភាពនៃអាជីវកម្ម ។
- វាយតម្លៃលើការបង្ហាញនៃទម្រង់និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យ ដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ ។

យើងខ្ញុំ ផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ច ស្តីពីបញ្ហាផ្សេងទៀត វិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀតដែលមានរួមបញ្ចូលទាំងចំណុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម ។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា ចំកាត់**

Lim Chew Teng

*Partner*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី 29 ខែ ឧសភា ឆ្នាំ 2020

# ឥណទានពលរដ្ឋរុងរឿង អិលធីឌី

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
## នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

| | | នាថ្ងៃទី 31 ខែ ធ្នូ | | នាថ្ងៃទី 31 ខែ ធ្នូ | |
|---|---|---|---|---|---|
| | | 2019 | 2018 | 2019 | 2018 |
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ពាន់រៀល (កំណត់សម្គាល់ 5) |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | 6 | 1,720,364 | 996,618 | 7,010,483 | 4,004,411 |
| ប្រាក់បញ្ញើ នៅធនាគារនានា | 7 | 12,500 | 12,500 | 50,938 | 50,225 |
| ប្រាក់តម្កល់តាមច្បាប់ | 8 | 154,432 | 154,432 | 629,310 | 620,508 |
| ឥណទានផ្តល់ដល់អតិថិជន-សុទ្ធ | 9 | 5,170,113 | 5,780,491 | 21,068,210 | 23,226,013 |
| ទ្រព្យសកម្មផ្សេងៗ | 10 | 113,312 | 99,520 | 461,747 | 399,871 |
| ទ្រព្យ និងបរិក្ខារ | 11 | 25,914 | 45,655 | 105,600 | 183,442 |
| ទ្រព្យសកម្មអរូបី | 12 | - | 404 | - | 1,623 |
| ពន្ធពន្យារជាទ្រព្យសកម្ម - សុទ្ធ | 15ក | 137,991 | 159,670 | 562,313 | 641,554 |
| ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំជាទ្រព្យសកម្ម | 15ខ | - | 16,476 | - | 66,201 |
| **ទ្រព្យសកម្មសរុប** | | 7,334,626 | 7,265,766 | 29,888,601 | 29,193,848 |
| **បំណុល និងមូលធន** | | | | | |
| បំណុល | | | | | |
| ប្រាក់កម្ចី | 13 | 302,000 | 585,492 | 1,230,650 | 2,352,507 |
| បំណុលផ្សេងៗ | 14 | 24,827 | 14,688 | 101,170 | 59,016 |
| បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | 15ខ | 30,337 | - | 123,623 | - |
| **បំណុលសរុប** | | 357,164 | 600,180 | 1,455,443 | 2,411,523 |
| មូលធន | | | | | |
| ដើមទុន | 18 | 3,088,645 | 3,088,645 | 12,468,860 | 12,468,860 |
| ប្រាក់ចំណេញរក្សាទុក | | 3,872,369 | 3,567,594 | 15,638,550 | 14,403,601 |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | 19 | 16,448 | 9,347 | 66,582 | 37,809 |
| ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | - | - | 259,166 | (127,945) |
| **មូលធនសរុប** | | 6,977,462 | 6,665,586 | 28,433,158 | 26,782,325 |
| **បំណុល និងមូលធនសរុប** | | 7,334,626 | 7,265,766 | 29,888,601 | 29,193,848 |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ។

# ធនាគារពាណិជ្ជកម្មក្រុងស្រីលង្កា ភីអិលស៊ី

## របាយការណ៍លទ្ធផលលម្អិត
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

| | កំណត់សម្គាល់ | 2019<br>ដុល្លារអាមេរិក | 2018<br>ដុល្លារអាមេរិក | 2019<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) | 2018<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) |
|---|---|---|---|---|---|
| **ចំណូលពីប្រតិបត្តិការ** | | | | | |
| ចំណូលពីការប្រាក់ | 18 | 1,164,133 | 1,626,056 | 4,717,067 | 6,577,397 |
| ចំណាយលើការប្រាក់ | 19 | (47,390) | (171,617) | (192,024) | (694,191) |
| ចំណូលការប្រាក់-សុទ្ធ | | 1,116,743 | 1,454,439 | 4,525,043 | 5,883,206 |
| ចំណូលពីប្រតិបត្តិការផ្សេងៗ | 20 | 269,550 | 85,661 | 1,092,217 | 346,499 |
| ចំណេញពីប្រតិបត្តិការសុទ្ធ | | 1,386,293 | 1,540,100 | 5,617,260 | 6,229,705 |
| ចំណាយលើបុគ្គលិក | 21 | (514,256) | (528,203) | (2,083,765) | (2,136,581) |
| រំលស់ | | (22,909) | (36,125) | (92,827) | (146,126) |
| ចំណាយប្រតិបត្តិការផ្សេងៗ | 22 | (367,232) | (376,157) | (1,488,025) | (1,521,555) |
| សំវិធានធនលើការខាតបង់លើឱនភាពនៃតម្លៃនៃឥណទានផ្តល់ដល់អតិថិជន | 10 | (88,347) | (367,026) | (357,982) | (1,484,620) |
| **ប្រាក់ចំណេញមុនដកពន្ធ** | | 393,549 | 232,589 | 1,594,661 | 940,823 |
| ចំណាយពន្ធលើប្រាក់ចំណេញ | 15គ | (81,673) | (70,235) | (330,939) | (284,101) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | 311,876 | 162,354 | 1,263,722 | 656,722 |
| *លទ្ធផល/(ខាត)លម្អិតផ្សេងៗ* | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | 387,111 | (127,945) |
| **លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | | 311,876 | 162,354 | 1,650,833 | 528,777 |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ។

# ឥណទានពលរដ្ឋរុងរឿង អិលធីឌី

## របាយការណ៍ស្តីពីបម្រែបម្រួលមូលធន
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

| | ដើមទុន | | ប្រាក់ចំណេញរក្សាទុក | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) |
| នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 | 3,088,645 | 12,468,860 | 3,414,587 | 13,784,688 | - | - | - | - | 6,503,232 | 26,253,548 |
| ***ប្រតិបត្តិការដែលបានទទួលស្គាល់ ដោយផ្ទាល់នៅក្នុងមូលធន*** | | | | | | | | | | |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុក ទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | (9,347) | (37,809) | 9,347 | 37,809 | - | - | - | - |
| **ប្រាក់ចំណេញលម្អិតសរុប** | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | 162,354 | 656,722 | - | - | - | - | 162,354 | 656,722 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | (127,945) | - | (127,945) |
| នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 | 3,088,645 | 12,468,860 | 3,567,594 | 14,403,601 | 9,347 | 37,809 | - | (127,945) | 6,665,586 | 26,782,325 |
| | | | | | | | | | | |
| នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2019 | 3,088,645 | 12,468,860 | 3,567,594 | 14,403,601 | 9,347 | 37,809 | - | (127,945) | 6,665,586 | 26,782,325 |
| ***ប្រតិបត្តិការដែលបានទទួលស្គាល់ ដោយផ្ទាល់នៅក្នុងមូលធន*** | | | | | | | | | | |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុក ទៅទុនបម្រុងតាមបទប្បញ្ញត្តិ | | | (7,101) | (28,773) | 7,101 | 28,773 | - | - | - | - |
| **ប្រាក់ចំណេញលម្អិតសរុប** | - | - | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | 311,876 | 1,263,722 | - | - | - | - | 311,876 | 1,263,722 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | 387,111 | - | 387,111 |
| នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 | 3,088,645 | 12,468,860 | 3,872,369 | 15,638,550 | 16,448 | 66,582 | - | 259,166 | 6,977,462 | 28,433,158 |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ។

# ឥណទានពលរដ្ឋរុងរឿង អិលធីឌី

## របាយការណ៍លំហូរទឹកប្រាក់
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

| | 2019<br>ដុល្លារអាមេរិក | 2018<br>ដុល្លារអាមេរិក | 2019<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) | 2018<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) |
|---|---|---|---|---|
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | 311,876 | 162,354 | 1,263,722 | 656,722 |
| *និយ័តភាពលើ៖* | | | | |
| ចំណាយពន្ធលើប្រាក់ចំណេញ | 81,673 | 70,235 | 330,939 | 284,101 |
| ចំណូលពីការប្រាក់ | (1,164,133) | (1,626,056) | (4,717,067) | (6,577,397) |
| ចំណាយលើការប្រាក់ | 47,390 | 171,617 | 192,024 | 694,191 |
| (ចំណេញ)/ខាតលើការប្តូររូបិយប័ណ្ណបរទេសមិនទាន់ទទួលស្គាល់ | (75,377) | 4,603 | (305,428) | 18,621 |
| រំលស់ | 22,909 | 36,125 | 92,827 | 146,126 |
| ការលុបចោលទ្រព្យ និង បរិក្ខារ | 2,332 | - | 9,450 | - |
| សំវិធានធនលើការខាតបង់ឱនភាពនៃតម្លៃនៃឥណទានផ្តល់ដល់អតិថិជន | 88,347 | 367,026 | 357,982 | 1,484,620 |
| សំវិធានធនលើអត្ថប្រយោជន៍និយោជិត | 18,009 | (5,781) | 72,972 | (23,384) |
| | (666,974) | (819,877) | (2,702,579) | (3,316,400) |
| *បម្រែបម្រួលនៃ៖* | | | | |
| ឥណទានផ្តល់ដល់អតិថិជន | 522,895 | 2,092,375 | 2,118,771 | 8,463,657 |
| ទ្រព្យសកម្មផ្សេងៗ | (13,792) | (36,220) | (55,885) | (146,510) |
| បំណុលផ្សេងៗ | 10,139 | (56,777) | 41,083 | (229,663) |
| | (147,732) | 1,179,501 | (598,610) | 4,771,084 |
| ការប្រាក់ដែលបានទទួល | 1,238,646 | 1,716,223 | 5,018,994 | 6,942,122 |
| ការប្រាក់ដែលបានបង់ | (47,547) | (224,017) | (192,660) | (906,149) |
| ពន្ធលើប្រាក់ចំណេញដែលបានបង់ | (13,181) | (78,742) | (53,409) | (318,511) |
| ការទូទាត់អត្ថប្រយោជន៍និយោជិត | (18,009) | (144,582) | (72,972) | (584,834) |
| **សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពប្រតិបត្តិការ** | 1,012,177 | 2,448,383 | 4,101,343 | 9,903,712 |

# ធនាគារពលរដ្ឋរុងរឿង អិលធីឌី

## របាយការណ៍លំហូរទឹកប្រាក់ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

| | 2019<br>ដុល្លារអាមេរិក | 2018<br>ដុល្លារអាមេរិក | 2019<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) | 2018<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) |
|---|---|---|---|---|
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | (5,096) | (7,106) | (20,649) | (28,744) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាព វិនិយោគ** | (5,096) | (7,106) | (20,649) | (28,744) |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | |
| សាច់ប្រាក់ទទួលបានប្រាក់កម្ចី | (283,335) | (2,805,420) | (1,148,073) | (11,347,924) |
| ការទូទាត់សងប្រាក់កម្ចី | - | 200,000 | - | 809,000 |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាព ហិរញ្ញប្បទាន** | (283,335) | (2,605,420) | (1,148,073) | (10,538,924) |
| **ការកើនឡើង/(ថយចុះ)សុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | 723,746 | (164,143) | 2,932,621 | (663,956) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី 1 ខែ មករា** | 996,618 | 1,160,761 | 4,004,411 | 4,685,992 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | 73,451 | (17,625) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី 31 ខែ ធ្នូ (កំណត់សម្គាល់6)** | 1,720,364 | 996,618 | 7,010,483 | 4,004,411 |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ ។

# ឥណទានពលរដ្ឋរុងរឿង អិលធីឌី

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

### 1. ព័ត៌មានអំពីក្រុមហ៊ុន

ឥណទានពលរដ្ឋរុងរឿង អិលធីឌី (ហៅកាត់ថា "ក្រុមហ៊ុន") អតីតជាអង្គភាពឥណទានរបស់សម្ព័ន្ធសមាគមន៍ម៉ាស៊ីនកិនស្រូវកម្ពុជា ។ ក្រុមហ៊ុន បានបង្កើតឡើងនៅព្រះរាជាណាចក្រកម្ពុជាក្រោមការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី 19 ខែ កក្កដា ឆ្នាំ 2005 ។ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើប្រតិបត្តិការជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅថ្ងៃទី 18 ខែ សីហា ឆ្នាំ 2005 ។ ក្រុមហ៊ុន បានទទួលអាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុអចិន្ត្រៃយ៍ពីធនាគារជាតិនៃកម្ពុជានៅថ្ងៃទី 24 ខែ មិថុនា ឆ្នាំ 2008 ។

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺការផ្តល់សេវាឥណទាន ដើម្បីធ្វើឲ្យកម្រិតជីវភាពរបស់ពលរដ្ឋកាន់តែមានភាពប្រសើរឡើង ក្នុងទិសដៅអភិវឌ្ឍជនបទតាមរយៈការិយាល័យកណ្តាលរបស់ក្រុមហ៊ុន ដែលមានទីតាំងនៅរាជធានីភ្នំពេញ និង សាខានៅតាមបណ្តាខេត្ត ចំនួន4 មានដូចជា ខេត្តតាកែវ ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ។

ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុនមានទីតាំងស្ថិតនៅអគារ 779A ផ្លូវកម្ពុជាក្រោម (128) សង្កាត់ ទឹកល្អក់ I ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 ក្រុមហ៊ុនមានបុគ្គលិកចំនួន 78 នាក់ (ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018: 91 នាក់) ។

### 2. មូលដ្ឋាននៃគណនេយ្យ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ស.រ.ទ.ហ.អ.ក) សម្រាប់សហគ្រាសធុនតូច និងមធ្យម ហៅកាត់ថា ("CIFRSs for SME") ។ នេះគឺជារបាយការណ៍ហិរញ្ញវត្ថុលើកដំបូងរបស់ក្រុមហ៊ុន ដែលត្រូវបានរៀបចំឡើងដោយអនុលោមទៅតាម ស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធុនតូច និងមធ្យមហើយផ្នែកទី35 អន្តរកាលឆ្ពោះទៅស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធុនតូច និងមធ្យមត្រូវបានអនុវត្ត។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុកាលពីការិយបរិច្ឆេទមុន របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ហៅកាត់ថា "ស្តង់ដារពីមុន" ។

ក្រុមហ៊ុនបានអនុវត្តនូវគោលនយោបាយគណនេយ្យ និងវិធីសាស្ត្រនៃការគណនា ប្រកបដោយសង្គតិភាពនៅគ្រប់ការិយបរិច្ឆេទដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្នុងការរៀបចំរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដំបូងនាថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 តាម ស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធុនតូច និងមធ្យម ។

# ធនាគារពាណិជ្ជកម្ម អេសធីស៊ី

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

### 2. មូលដ្ឋាននៃគណនេយ្យ (ត)

ការពន្យល់ពីរបៀបនៃការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធុនតូច និងមធ្យម ដែលបានប៉ះពាល់ដល់ការរាយការណ៍ពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ 27 ។

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល និងផ្តល់សិទ្ធិផ្សាយនៅថ្ងៃទី 29 ខែ ឧសភា ឆ្នាំ 2020 ។

ព័ត៌មានលម្អិតទាក់ទងនឹងគោលនយោបាយគណនេយ្យសំខាន់ៗរបស់ក្រុមហ៊ុន ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ 26 ។

### 3. រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់កំណត់បង្ហាញ

ក្រុមហ៊ុនធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រា រាល់បញ្ជីគណនេយ្យរបស់ខ្លួនផ្អែកលើរូបិយប័ណ្ណប្រាក់ដុល្លារអាមេរិក ។ អ្នកគ្រប់គ្រង បានកំណត់ប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណមុខងារ និងជារូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ ព្រោះវាឆ្លុះបញ្ចាំងពីភាពចាំបាច់នៃសេដ្ឋកិច្ច ប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន ។

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន ។ តួលេខទាំងអស់ ត្រូវបានបង្គត់ចំនួនមួយដុល្លារអាមេរិក ឬមួយពាន់រៀលដែលជិតបំផុត បើមិនដូច្នេះទេ លុះត្រាតែមានការបង្ហាញផ្សេងពីនោះ ។

### 4. ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ អ្នកគ្រប់គ្រងធ្វើការវិនិច្ឆ័យ ប៉ាន់ស្មាន និងសន្មតដែលមានផលប៉ះពាល់ដល់ការអនុវត្តនូវគោលនយោបាយគណនេយ្យ និងចំនួននៃទ្រព្យសកម្ម បំណុល ចំណូល និងចំណាយដែលបានរាយការណ៍ ។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនោះ ។

ការប៉ាន់ស្មាន និងការសន្មត់ដែលពាក់ព័ន្ធ ត្រូវបានត្រួតពិនិត្យជាប្រចាំ ។ ការកែប្រែលើការប៉ាន់ស្មាន ត្រូវបានទទួលស្គាល់តាមវិធិសាស្រ្តទស្សនៈវិស័យ ។

ព័ត៌មានអំពីភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន ដែលមានហានិភ័យជាសារវន្ត ដែលអាចធ្វើឲ្យមាននិយ័តភាពនៅក្នុងការិយបរិច្ឆេទ ដែលបានបញ្ចប់នៅថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 ត្រូវបានកំណត់ដូចខាងក្រោម ទាក់ទងនឹងឱនភាពនៃតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុ ។

កំណត់សម្គាល់ 26ឆ(vii)៖ ការកំណត់អត្តសញ្ញាណ និងការវាស់វែងលើឱនភាពនៃតម្លៃ ។

# ធនាគារពាណិជ្ជកម្មអេស៊ីលីដា ពិអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

## 5. ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ។ ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល ត្រូវបានធ្វើឡើងដើម្បីអនុវត្តទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ទ្រព្យសកម្ម និងបំណុលត្រូវបានប្តូរតាមអត្រានាកាលបរិច្ឆេទរាយការណ៍ និង ដើមទុន ត្រូវបានប្តូរតាមអត្រាប្រវត្តិសាស្ត្រ ។ របាយការណ៍លទ្ធផលលម្អិត និងរបាយការណ៍លំហូរទឹកប្រាក់ត្រូវបានប្តូរទៅជាប្រាក់រៀលដោយប្រើប្រាស់អត្រាមធ្យមនៅក្នុងការិយបរិច្ឆេទ ។ ភាពខុសគ្នាដែលកើតឡើងពីការប្តូររូបិយប័ណ្ណ ត្រូវបានទទួលស្គាល់ជា "ទុនបម្រុងពីការប្តូររូបិយប័ណ្ណ" នៅក្នុងរបាយការណ៍លទ្ធផលលម្អិត ។

ក្រុមហ៊ុនប្រើប្រាស់អត្រាប្តូររូបិយប័ណ្ណដូចខាងក្រោមៈ

| | | | អត្រានាកាលបរិច្ឆេទរាយការណ៍ | អត្រាមធ្យម |
|---|---|---|---|---|
| ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 | 1 ដុល្លារអាមេរិក | = | 4,075 រៀល | 4,052 រៀល |
| ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 | 1 ដុល្លារអាមេរិក | = | 4,018 រៀល | 4,045 រៀល |
| ថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 | 1 ដុល្លារអាមេរិក | = | 4,037 រៀល | មិនប្រើ |

## 6. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | នាថ្ងៃទី 31 ខែធ្នូ | | នាថ្ងៃទី 31 ខែធ្នូ | |
|---|---|---|---|---|
| | 2019 | 2018 | 2019 | 2018 |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ពាន់រៀល (កំណត់សម្គាល់ 5) |
| សាច់ប្រាក់នៅក្នុងដៃ | 84,504 | 71,790 | 344,354 | 288,452 |
| សមតុល្យជាមួយធនាគារនានា | 1,635,860 | 924,828 | 6,666,129 | 3,715,959 |
| | 1,720,364 | 996,618 | 7,010,483 | 4,004,411 |

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

## 7. ប្រាក់បញ្ញើ នៅធនាគារនានា

| | នាថ្ងៃទី 31 ខែ ធ្នូ | | នាថ្ងៃទី 31 ខែ ធ្នូ | |
|---|---|---|---|---|
| | 2019 | 2018 | 2019 | 2018 |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ពាន់រៀល (កំណត់សម្គាល់ 5) |
| ប្រាក់បញ្ញើមានកាលកំណត់ (មិនមែនជាសាច់ប្រាក់សមមូល) | 12,500 | 12,500 | 50,938 | 50,225 |

ប្រាក់តម្កល់នៅធនាគារ ត្រូវបានវិភាគបន្ថែមដូចខាងក្រោម៖

| | នាថ្ងៃទី 31 ខែ ធ្នូ | | នាថ្ងៃទី 31 ខែ ធ្នូ | |
|---|---|---|---|---|
| | 2019 | 2018 | 2019 | 2018 |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ពាន់រៀល (កំណត់សម្គាល់ 5) |
| ក. តាមកាលកំណត់: | | | | |
| > 3 ទៅ 12 ខែ | 12,500 | 12,500 | 50,938 | 50,225 |

ខ. តាមអត្រាការប្រាក់ (ក្នុង 1 ឆ្នាំ)៖

| | 2019 | 2018 |
|---|---|---|
| ប្រាក់បញ្ញើមានកាលកំណត់ | 3.25% | 3.25% |

# ឥណទានពលរដ្ឋរុងរឿង អិលធីឌី

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

### 8. ប្រាក់តម្កល់តាមច្បាប់

យោងតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ7-01-136 ចុះថ្ងៃទី 15 ខែ តុលា ឆ្នាំ 2001 គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតម្រូវឲ្យរក្សាប្រាក់តម្កល់តាមច្បាប់ចំនួន5%នៃដើមទុនចុះបញ្ជីរបស់ខ្លួនជាមួយធនាគារជាតិនៃកម្ពុជា ។ ប្រាក់តម្កល់នេះ គឺមិនអាចប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ខ្លួនបានឡើយ ប៉ុន្តែក្រុមហ៊ុនអាចដកវិញបាន នៅពេលដែលក្រុមហ៊ុនសម្រេចចិត្តឈប់ធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយស្ម័គ្រចិត្ត ។

ប្រាក់តម្កល់តាមច្បាប់ រក្សានៅធនាគារជាតិនៃកម្ពុជាជាប្រាក់ដុល្លារអាមេរិកនេះ ទទួលបានអត្រាការប្រាក់ 3/8 នៃ Libor rate សម្រាប់រយៈពេល 6ខែ ។

### 9. ឥណទានផ្តល់ដល់អតិថិជន-សុទ្ធ

| | នាថ្ងៃទី 31 ខែ ធ្នូ | | នាថ្ងៃទី 31 ខែ ធ្នូ | |
|---|---|---|---|---|
| | 2019 | 2018 | 2019 | 2018 |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ពាន់រៀល (កំណត់សម្គាល់ 5) |
| ឥណទានឯកត្តជន | 5,697,001 | 6,664,417 | 23,215,278 | 26,777,628 |
| ឥណទានបុគ្គលិក | 44,047 | 5,824 | 179,492 | 23,401 |
| | 5,741,048 | 6,670,241 | 23,394,770 | 26,801,029 |
| ដកៈ សំវិធានធននៃការខាតបង់លើឱនភាពនៃតម្លៃ | (570,935) | (889,750) | (2,326,560) | (3,575,016) |
| | 5,170,113 | 5,780,491 | 21,068,210 | 23,226,013 |

បម្រែបម្រួលនៃសំវិធានធនការខាតបង់លើឱនភាពនៃតម្លៃមានដូចខាងក្រោមៈ

| | នាថ្ងៃទី 31 ខែ ធ្នូ | | នាថ្ងៃទី 31 ខែ ធ្នូ | |
|---|---|---|---|---|
| | 2019 | 2018 | 2019 | 2018 |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ពាន់រៀល (កំណត់សម្គាល់ 5) |
| នាថ្ងៃទី 1 ខែ មករា | 889,750 | 868,561 | 3,575,016 | 3,506,381 |
| សំវិធានធនបន្ថែមនៅក្នុងឆ្នាំ | 88,347 | 367,026 | 357,982 | 1,484,620 |
| ការលុបចោល | (407,162) | (345,837) | (1,649,820) | (1,398,911) |
| លម្អៀងលើការប្តូររូបិយប័ណ្ណ | - | - | 43,382 | (17,074) |
| នាថ្ងៃទី 31 ខែ ធ្នូ | 570,935 | 889,750 | 2,326,560 | 3,575,016 |

## 9. ឥណទានផ្តល់ដល់អតិថិជន-សុទ្ធ (ត)

ឥណទានផ្តល់ដល់អតិថិជនត្រូវបានវិភាគដូចខាងក្រោម៖

| | នាថ្ងៃទី 31 ខែ ធ្នូ | | នាថ្ងៃទី 31 ខែ ធ្នូ | |
|---|---|---|---|---|
| | 2019 | 2018 | 2019 | 2018 |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ពាន់រៀល (កំណត់សម្គាល់ 5) |
| **(ក) តាមកាលកំណត់៖** | | | | |
| រយៈពេល 1 ខែ | - | 168,451 | - | 676,836 |
| 2 ទៅ 3 ខែ | - | 110,503 | - | 444,002 |
| 4 ទៅ 12 ខែ | 1,874,614 | 1,474,998 | 7,639,052 | 5,926,542 |
| លើស 12 ខែ | 3,866,434 | 4,916,289 | 15,755,718 | 19,753,649 |
| | 5,741,048 | 6,670,241 | 23,394,770 | 26,801,029 |
| **(ខ) តាមវិស័យសេដ្ឋកិច្ច៖** | | | | |
| កសិកម្ម | 2,929,753 | 4,388,186 | 11,938,743 | 17,631,732 |
| សេវាកម្ម | 80,580 | 114,285 | 328,364 | 459,197 |
| ផ្សេងៗ | 2,730,715 | 2,167,770 | 11,127,663 | 8,710,100 |
| | 5,741,048 | 6,670,241 | 23,394,770 | 26,801,029 |
| **(គ) តាមនិវាសនដ្ឋាន៖** | | | | |
| និវាសនជន | 5,741,048 | 6,670,241 | 23,394,770 | 26,801,029 |
| **(ឃ) តាមទំនាក់ទំនង៖** | | | | |
| អតិថិជនខាងក្រៅ | 5,011,541 | 6,056,031 | 20,422,028 | 24,333,133 |
| ភាគីពាក់ព័ន្ធ | 685,460 | 608,386 | 2,793,250 | 2,444,495 |
| ឥណទានបុគ្គលិក | 44,047 | 5,824 | 179,492 | 23,401 |
| | 5,741,048 | 6,670,241 | 23,394,770 | 26,801,029 |

# ធនាគារពាណិជ្ជកម្ម អេស ប៊ី អាយ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

### 9. ឥណទានផ្តល់ដល់អតិថិជន-សុទ្ធ (ត)

ឥណទានផ្តល់ដល់អតិថិជនត្រូវបានវិភាគដូចខាងក្រោម៖ (ត)

| | នាថ្ងៃទី 31 ខែ ធ្នូ | | នាថ្ងៃទី 31 ខែ ធ្នូ | |
|---|---|---|---|---|
| | 2019 | 2018 | 2019 | 2018 |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ពាន់រៀល (កំណត់សម្គាល់ 5) |
| (ង) តាមទីតាំងភូមិសាស្ត្រ៖ | | | | |
| ភ្នំពេញ | 755,913 | 614,267 | 3,080,345 | 2,468,125 |
| បាត់ដំបង | 2,411,619 | 3,439,544 | 9,827,347 | 13,820,087 |
| ពោធិ៍សាត់ | 798,178 | 1,098,944 | 3,252,576 | 4,415,558 |
| តាកែវ | 1,007,792 | 768,291 | 4,106,752 | 3,086,993 |
| បន្ទាយមានជ័យ | 767,546 | 749,195 | 3,127,750 | 3,010,266 |
| | 5,741,048 | 6,670,241 | 23,394,770 | 26,801,029 |
| (ច) តាមរូបិយប័ណ្ណ៖ | | | | |
| ប្រាក់រៀល | 550,459 | 642,528 | 2,243,120 | 2,581,678 |
| ប្រាក់ដុល្លារអាមេរិក | 4,242,219 | 5,084,404 | 17,287,042 | 20,429,135 |
| ប្រាក់បាត | 948,370 | 943,309 | 3,864,608 | 3,790,216 |
| | 5,741,048 | 6,670,241 | 23,394,770 | 26,801,029 |

| | 2019 | 2018 |
|---|---|---|
| (ឆ) តាមអត្រាការប្រាក់ (ប្រចាំឆ្នាំ) | | |
| អតិថិជនខាងក្រៅ | 12.00% - 32.40% | 17.40% - 33.60% |
| ភាគីពាក់ព័ន្ធ | 12.00% | 12.00% |
| ឥណទានបុគ្គលិក | 12.00% | 12.00% |

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

## 10. ទ្រព្យសកម្មផ្សេងៗ

| | នាថ្ងៃទី 31 ខែ ធ្នូ | | នាថ្ងៃទី 31 ខែ ធ្នូ | |
|---|---|---|---|---|
| | ឆ្នាំ 2019<br>ដុល្លារអាមេរិក | ឆ្នាំ 2018<br>ដុល្លារអាមេរិក | ឆ្នាំ 2019<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) | ឆ្នាំ 2018<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) |
| ចំណាយបង់មុន | 28,284 | 26,988 | 115,257 | 108,438 |
| បុរេប្រទានទៅម្ចាស់ភាគហ៊ុន (*) | 70,500 | 60,300 | 287,288 | 242,285 |
| ផ្សេងៗ | 14,528 | 12,232 | 59,202 | 49,148 |
| | 113,312 | 99,520 | 461,747 | 399,871 |

(*) បុរេប្រទានទៅម្ចាស់ភាគហ៊ុនគឺគ្មានការធានា គ្មានការប្រាក់ និង សងត្រលប់តាមតំរូវការ ។

# ធនាគារពាណិជ្ជរុងរឿង អិលធីឌី

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

## 11. ទ្រព្យ និងបរិក្ខារ

| 2019 | ការកែលំអអគារ<br>ដុល្លារអាមេរិក | យានយន្ត<br>ដុល្លារអាមេរិក | គ្រឿងសង្ហារឹម និង គ្រឿងបំពាក់<br>ដុល្លារអាមេរិក | កុំព្យូទ័រ និងបរិក្ខារការិយាល័យ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក | សរុប<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) |
|---|---|---|---|---|---|---|
| **ថ្លៃដើម** | | | | | | |
| នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2019 | 9,093 | 14,125 | 32,417 | 68,772 | 124,407 | 499,867 |
| ការទិញបន្ថែម | 214 | - | 938 | 3,944 | 5,096 | 20,649 |
| ការលុបចោល | (6,149) | (1,777) | (16,094) | (24,056) | (48,076) | (194,804) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | 6,103 |
| នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 | 3,158 | 12,348 | 17,261 | 48,660 | 81,427 | 331,815 |
| ដក: **រំលស់បង្គរ** | | | | | | |
| នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2019 | 7,672 | 5,415 | 23,213 | 42,452 | 78,752 | 316,425 |
| រំលស់ក្នុងការិយបរិច្ឆេទ | 630 | 2,558 | 5,773 | 13,544 | 22,505 | 91,190 |
| ការលុបចោល | (6,124) | (769) | (16,094) | (22,757) | (45,744) | (185,354) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | 3,954 |
| នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 | 2,178 | 7,204 | 12,892 | 33,239 | 55,513 | 226,215 |
| **តម្លៃយោង** | | | | | | |
| នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 | 980 | 5,144 | 4,369 | 15,421 | 25,914 | 105,600 |

# ធនាគារពាណិជ្ជកម្មក្រៅប្រទេស អេសប៊ីអាយ

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

### 11. ទ្រព្យ និងបរិក្ខារ (ត)

| 2018 | ការកែលំអអគារ<br>ដុល្លារអាមេរិក | យានយន្ត<br>ដុល្លារអាមេរិក | គ្រឿងសង្ហារឹម និង<br>គ្រឿងបំពាក់<br>ដុល្លារអាមេរិក | កុំព្យូទ័រ និងបរិក្ខារ<br>ការិយាល័យ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក | សរុប<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) |
|---|---|---|---|---|---|---|
| **ថ្លៃដើម** | | | | | | |
| នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 | 9,093 | 23,248 | 64,047 | 100,883 | 197,271 | 796,383 |
| ការទិញបន្ថែម | - | - | 299 | 6,807 | 7,106 | 28,744 |
| ការលុបចោល | - | (9,123) | (31,929) | (38,918) | (79,970) | (323,479) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | (1,781) |
| នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 | 9,093 | 14,125 | 32,417 | 68,772 | 124,407 | 499,867 |
| ដក: **រំលស់បង្គរ** | | | | | | |
| នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 | 5,536 | 10,954 | 43,596 | 64,198 | 124,284 | 501,735 |
| រំលស់ក្នុងការិយបរិច្ឆេទ | 2,136 | 3,584 | 11,546 | 17,172 | 34,438 | 139,302 |
| ការលុបចោល | - | (9,123) | (31,929) | (38,918) | (79,970) | (323,479) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | (1,133) |
| នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 | 7,672 | 5,415 | 23,213 | 42,452 | 78,752 | 316,425 |
| **តម្លៃយោង** | | | | | | |
| នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 | 1,421 | 8,710 | 9,204 | 26,320 | 45,655 | 183,442 |

# ធនាគារពាណិជ្ជក្រៅប្រទេស អិលធីឌី

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

## 12. ទ្រព្យសកម្មអរូបី

| | កុំព្យូទ័រសូហ្វវែរ | | | |
|---|---|---|---|---|
| | 2019<br>ដុល្លារអាមេរិក | 2018<br>ដុល្លារអាមេរិក | 2019<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) | 2018<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) |
| **ថ្លៃដើម** | | | | |
| នាថ្ងៃទី 1 ខែ មករា | 6,750 | 6,750 | 27,122 | 27,250 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | 384 | (128) |
| នាថ្ងៃទី 31 ខែ ធ្នូ | 6,750 | 6,750 | 27,506 | 27,122 |
| ដក: **រំលស់បង្គរ** | | | | |
| នាថ្ងៃទី 1 ខែ មករា | 6,346 | 4,659 | 25,499 | 18,808 |
| រំលស់សម្រាប់ការិយបរិច្ឆេទ | 404 | 1,687 | 1,637 | 6,824 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | 370 | (133) |
| នាថ្ងៃទី 31 ខែ ធ្នូ | 6,750 | 6,346 | 27,506 | 25,499 |
| **តម្លៃយោង** | | | | |
| នាថ្ងៃទី 31 ខែ ធ្នូ | - | 404 | - | 1,623 |

## 13. ប្រាក់កម្ចី

| | នាថ្ងៃទី 31 ខែ ធ្នូ | | នាថ្ងៃទី 31 ខែ ធ្នូ | |
|---|---|---|---|---|
| | 2019<br>ដុល្លារអាមេរិក | 2018<br>ដុល្លារអាមេរិក | 2019<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) | 2018<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) |
| ភាគីពាក់ព័ន្ធ | 302,000 | 302,000 | 1,230,650 | 1,213,436 |
| ភាគីមិនពាក់ព័ន្ធ | - | 283,492 | - | 1,139,071 |
| | 302,000 | 585,492 | 1,230,650 | 2,352,507 |

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

## 13. ប្រាក់កម្ចី (ត)

ប្រាក់កម្ចីត្រូវបានធ្វើការវិភាគដូចខាងក្រោម៖

| | នាថ្ងៃទី 31 ខែ ធ្នូ | | នាថ្ងៃទី 31 ខែ ធ្នូ | |
|---|---|---|---|---|
| | 2019 | 2018 | 2019 | 2018 |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ពាន់រៀល (កំណត់សម្គាល់ 5) |
| ក. តាមកាលកំណត់: | | | | |
| ពី 3 ទៅ 12 ខែ | - | 83,492 | - | 335,471 |
| ពី 1 ទៅ 5 ឆ្នាំ | 302,000 | 502,000 | 1,230,650 | 2,017,036 |
| | 302,000 | 585,492 | 1,230,650 | 2,352,507 |

| | 2019 | 2018 |
|---|---|---|
| ខ. តាមអត្រាការប្រាក់ (ក្នុងមួយឆ្នាំ)៖ | | |
| ដុល្លារអាមេរិក | 9.41% | 9.41% - 11.05% |

## 14. បំណុលផ្សេងៗ

| | នាថ្ងៃទី 31 ខែ ធ្នូ | | នាថ្ងៃទី 31 ខែ ធ្នូ | |
|---|---|---|---|---|
| | 2019 | 2018 | 2019 | 2018 |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ពាន់រៀល (កំណត់សម្គាល់ 5) |
| បំណុលពន្ធផ្សេងៗ | 3,606 | 5,701 | 14,694 | 22,907 |
| បំណុលផ្សេងៗ | 21,221 | 8,987 | 86,476 | 36,109 |
| | 24,827 | 14,688 | 101,170 | 59,016 |

# ធនាគារពាណិជ្ជកម្មក្រុងថៃ អិលធីឌី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

## 15. ពន្ធលើប្រាក់ចំណេញ

### ក. ពន្ធពន្យារជាទ្រព្យសកម្ម - សុទ្ធ

| | នាថ្ងៃទី 31 ខែ ធ្នូ | | នាថ្ងៃទី 31 ខែ ធ្នូ | |
|---|---|---|---|---|
| | 2019 | 2018 | 2019 | 2018 |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ពាន់រៀល (កំណត់សម្គាល់ 5) |
| ពន្ធពន្យារលើទ្រព្យសកម្ម - សុទ្ធ | 137,991 | 159,670 | 562,313 | 641,554 |

ពន្ធពន្យារជាទ្រព្យសកម្ម/(បំណុល)កើតឡើងពីគណនីដូចខាងក្រោម៖

| | 2019 | | 2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ពាន់រៀល (កំណត់សម្គាល់ 5) |
| សំវិធានធនលើឱនភាពនៃតម្លៃ | 93,238 | 129,982 | 379,945 | 522,267 |
| ចំណូលមិនទាន់បានទទួលស្គាល់ | 35,331 | 36,052 | 143,973 | 144,857 |
| រំលស់ | 4,074 | 3,364 | 16,602 | 13,517 |
| (ចំណេញ)/ខាតពីការប្តូររូបិយប័ណ្ណ ដែលមិនទាន់បានទទួលស្គាល់ | 5,348 | (9,728) | 21,793 | (39,087) |
| | 137,991 | 159,670 | 562,313 | 641,554 |

បម្រែបម្រួលនៃពន្ធពន្យារជាទ្រព្យសកម្មមានដូចខាងក្រោម៖

| | 2019 | 2018 | 2019 | 2018 |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ពាន់រៀល (កំណត់សម្គាល់ 5) |
| នាថ្ងៃទី 1 មករា | 159,670 | 192,080 | 641,554 | 775,427 |
| ការទទួលស្គាល់ក្នុងចំណេញ ឬ ខាត | (21,679) | (32,410) | (87,843) | (131,098) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | 8,602 | (2,775) |
| នាថ្ងៃទី 31 ខែ ធ្នូ | 137,991 | 159,670 | 562,313 | 641,554 |

## 15. ពន្ធលើប្រាក់ចំណេញ (ត)

### ខ បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ/ (ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំជាទ្រព្យសកម្ម)

| | 2019<br>ដុល្លារអាមេរិក | 2018<br>ដុល្លារអាមេរិក | 2019<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) | 2018<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) |
|---|---|---|---|---|
| នាថ្ងៃទី 1 មករា | (16,476) | 24,441 | (66,201) | 98,668 |
| ចំណាយពន្ធលើប្រាក់ចំណេញ | 59,994 | 37,825 | 243,096 | 153,003 |
| ពន្ធលើប្រាក់ចំណេញបានបង់ | (13,181) | (78,742) | (53,409) | (318,511) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | 137 | 639 |
| នាថ្ងៃទី 31 ខែ ធ្នូ | 30,337 | (16,476) | 123,623 | (66,201) |

អនុលោមតាមច្បាប់សារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញដោយគណនាតាមអត្រា 20% នៃប្រាក់ចំណេញជាប់ពន្ធ ឬក៏បង់ពន្ធអប្បបរមាដោយគណនាតាមអត្រា 1% នៃប្រាក់ចំណូលដុល នៅពេលដែលពន្ធមួយណាមានចំនួនធំជាង ។

### គ ចំណាយពន្ធលើប្រាក់ចំណូល

| | 2019<br>ដុល្លារអាមេរិក | 2018<br>ដុល្លារអាមេរិក | 2019<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) | 2018<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) |
|---|---|---|---|---|
| ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | 59,994 | 37,825 | 243,096 | 153,003 |
| ពន្ធពន្យា | 21,679 | 32,410 | 87,843 | 131,098 |
| ចំណាយពន្ធលើប្រាក់ចំណូល | 81,673 | 70,235 | 330,939 | 284,101 |

# ធនាគារពាណិជ្ជក្រៅប្រទេស ខេមបូឌីយ៉ា

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

## 15. ពន្ធលើប្រាក់ចំណេញ (ត)

គ ចំណាយពន្ធលើប្រាក់ចំណូល (ត)

ការផ្ទៀងផ្ទាត់ពន្ធលើប្រាក់ចំណេញដែលត្រូវបានគណនាតាមអត្រាពន្ធផ្លូវការ 20% ចំពោះចំណាយពន្ធលើប្រាក់ចំណេញដូចបានបង្ហាញនៅក្នុងប្រាក់ចំណេញ ឬខាត ដូចខាងក្រោម:

| | 2019 | | | 2018 | | |
|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | % | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | % |
| ប្រាក់ចំណេញមុនដកពន្ធ | 393,549 | 1,594,661 | | 232,589 | 940,823 | |
| ពន្ធលើប្រាក់ចំណេញផ្អែកតាមអត្រាពន្ធជាផ្លូវការ 20% | 78,710 | 318,932 | 20% | 46,518 | 188,165 | 20% |
| ចំណាយមិនអាចកាត់កងបាន | 2,963 | 12,007 | 1% | 2,384 | 9,643 | 1% |
| ផ្សេងៗ | - | - | - | 21,333 | 86,293 | 9% |
| ចំណាយពន្ធលើប្រាក់ចំណេញ | 81,673 | 330,939 | 21% | 70,235 | 284,101 | 30% |

ការគណនាចំណាយពន្ធលើប្រាក់ចំណេញនឹងត្រូវមានការត្រួតពិនិត្យ និងអនុម័តដោយអាជ្ញាធរពន្ធដារ ។

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

## 16. ដើមទុន

| | នាថ្ងៃទី 31 ខែ ធ្នូ | | នាថ្ងៃទី 31 ខែ ធ្នូ | |
|---|---|---|---|---|
| | 2019 | 2018 | 2019 | 2018 |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ពាន់រៀល (កំណត់សម្គាល់ 5) |
| ដើមទុនបានចុះបញ្ជី និងបានបង់រួច ទាំងស្រុង ចំនួន 25,955 ភាគហ៊ុន និងមានតម្លៃចារឹក119ដុល្លារ អាមេរិកក្នុងមួយភាគហ៊ុន | | | | |
| ឧកញ៉ា ភូ ពុយ (100%) | 3,088,645 | 3,088,645 | 12,468,860 | 12,468,860 |

## 17. ទុនបម្រុងតាមបទប្បញ្ញត្តិ

ទុនបម្រុងតាមបទប្បញ្ញត្តិ តំណាងឲ្យភាពខុសគ្នានៃសំវិធានធនរវាងឱនភាពលើតម្លៃនៃឥណទានដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធនតូច និងមធ្យម និងសំវិធានធនតាមបទប្បញ្ញត្តិដោយអនុលោមតាមធនាគារជាតិនៃកម្ពុជា ។

## 18. ចំណូលពីការប្រាក់

| | 2019 | 2018 | 2019 | 2018 |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ពាន់រៀល (កំណត់សម្គាល់ 5) |
| ឥណទានផ្តល់ដល់អតិថិជន | 1,162,847 | 1,624,430 | 4,711,856 | 6,570,820 |
| ប្រាក់បញ្ញើនៅធនាគារនានា | 1,286 | 1,626 | 5,211 | 6,577 |
| | 1,164,133 | 1,626,056 | 4,717,067 | 6,577,397 |

## 19. ចំណាយលើការប្រាក់

| | 2019 | 2018 | 2019 | 2018 |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 5) | ពាន់រៀល (កំណត់សម្គាល់ 5) |
| ការប្រាក់នៃប្រាក់កម្ចី | 47,390 | 171,617 | 192,024 | 694,191 |

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

## 20. ចំណូលផ្សេងៗ

| | 2019 ដុល្លារអាមេរិក | 2018 ដុល្លារអាមេរិក | 2019 ពាន់រៀល (កំណត់សម្គាល់ 5) | 2018 ពាន់រៀល (កំណត់សម្គាល់ 5) |
|---|---|---|---|---|
| ការប្រមូលបានមកវិញពីឥណទានដែលបានលុបចោល | 160,343 | 57,299 | 649,710 | 231,775 |
| ចំណេញពីការប្តូររូបិយប័ណ្ណបរទេស | 75,377 | - | 305,428 | - |
| ចំណូលផ្សេងៗ | 33,830 | 28,362 | 137,079 | 114,724 |
| | 269,550 | 85,661 | 1,092,217 | 346,499 |

## 21. ចំណាយលើបុគ្គលិក

| | 2019 ដុល្លារអាមេរិក | 2018 ដុល្លារអាមេរិក | 2019 ពាន់រៀល (កំណត់សម្គាល់ 5) | 2018 ពាន់រៀល (កំណត់សម្គាល់ 5) |
|---|---|---|---|---|
| ប្រាក់បៀវត្សរ៍ | 481,249 | 520,614 | 1,950,020 | 2,105,884 |
| អត្ថប្រយោជន៍ផ្សេងៗ | 18,009 | (5,781) | 72,972 | (23,384) |
| ចំណាយលើការបណ្តុះបណ្តាល | 5,533 | 2,411 | 22,420 | 9,752 |
| ផ្សេងៗ | 9,465 | 10,959 | 38,353 | 44,329 |
| | 514,256 | 528,203 | 2,083,765 | 2,136,581 |

# ធនាគារពលរដ្ឋខេមរៀង អិលធីឌី

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

## 22. ចំណាយប្រតិបត្តិការផ្សេងៗ

| | 2019<br>ដុល្លារអាមេរិក | 2018<br>ដុល្លារអាមេរិក | 2019<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) | 2018<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) |
|---|---|---|---|---|
| ចំណាយលើការជួល | 87,798 | 92,533 | 355,757 | 374,296 |
| កម្រៃក្រុមប្រឹក្សាភិបាល | 53,000 | 50,600 | 214,756 | 204,677 |
| កម្រៃវិជ្ជាជីវៈ | 63,321 | 42,926 | 256,577 | 173,636 |
| ចំណាយប្រេងឥន្ធនៈ និង ប្រតិបត្តិការយានយន្ត | 30,664 | 40,497 | 124,251 | 163,810 |
| ចំណាយលើការធ្វើដំណើរ និងដឹកជញ្ជូន | 27,125 | 24,613 | 109,911 | 99,560 |
| ចំណាយលើការទំនាក់ទំនង | 16,735 | 18,828 | 67,810 | 76,159 |
| ចំណាយទឹក ភ្លើង | 15,701 | 16,610 | 63,620 | 67,187 |
| ចំណាយលើធានារ៉ាប់រង | 10,016 | 11,009 | 40,585 | 44,530 |
| ចំណាយការកម្សាន្ត | 9,133 | 5,045 | 37,007 | 20,407 |
| ចំណាយទីផ្សារ និង ការផ្សាយពាណិជ្ជកម្ម | 5,268 | 1,869 | 21,346 | 7,560 |
| ចំណាយលើការបោះពុម្ពនិង សម្ភារ | 5,099 | 12,223 | 20,661 | 49,442 |
| កម្រៃសមាជិកភាព | 3,447 | 3,315 | 13,967 | 13,409 |
| ទ្រព្យសកម្មដែលមានតម្លៃទាប | 2,979 | 4,220 | 12,071 | 17,070 |
| ចំណាយលើសោហ៊ុយធនាគារ | 2,876 | 7,472 | 11,654 | 30,224 |
| ចំណាយលើការពិន័យ | 1,230 | 1,835 | 4,984 | 7,423 |
| ចំណាយជួសជុល និងថែទាំ | 458 | 938 | 1,856 | 3,794 |
| ខាតលើការប្តូររូបិយប័ណ្ណបរទេស | - | 4,603 | - | 18,621 |
| ចំណាយផ្សេងៗ | 32,382 | 37,021 | 131,212 | 149,750 |
| | 367,232 | 376,157 | 1,488,025 | 1,521,555 |

# ធនាគារពលរដ្ឋខេមរើង អិលធីឌី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

## 23. សម្ព័ន្ធញាតិ

### ក. អត្តសញ្ញាណរបស់សម្ព័ន្ធញាតិ

ទំនាក់ទំនាក់របស់សម្ព័ន្ធញាតិជាមួយនិងក្រុមហ៊ុន មានដូចខាងក្រោម៖

| **ទំនាក់ទំនង** | **សម្ព័ន្ធញាតិ** |
|---|---|
| ភាគទុនិក | យោងតាមកំណត់សម្គាល់ 16 |
| អ្នកគ្រប់គ្រងសំខាន់ៗ | រាល់អភិបាលនៃក្រុមហ៊ុនដែលជាអ្នកធ្វើការសម្រេចចិត្តសំខាន់ៗ ដែលទាក់ទងទៅនឹងទិសដៅយុទ្ធសាស្ត្រ និងបុគ្គលិកគណៈគ្រប់គ្រងជាន់ខ្ពស់របស់ក្រុមហ៊ុន (រួមបញ្ចូលទាំងសមាជិកគ្រួសារ) |

### ខ. ប្រតិបត្តិការនិងសមតុល្យជាមួយសម្ព័ន្ធញាតិ

***(i) ប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ***

| | 2019<br>ដុល្លារអាមេរិក | 2018<br>ដុល្លារអាមេរិក | 2019<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) | 2018<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) |
|---|---|---|---|---|
| ចំណូលពីការប្រាក់ | 50,881 | 5,363 | 207,341 | 21,693 |
| ចំណាយការប្រាក់ | 28,235 | 48,113 | 114,409 | 194,617 |
| ការទូទាត់ប្រាក់កម្ចី | - | (700,000) | - | (2,831,500) |

***(ii) អត្ថប្រយោជន៍របស់អ្នកគ្រប់គ្រងសំខាន់ៗ***

| | 2019<br>ដុល្លារអាមេរិក | 2018<br>ដុល្លារអាមេរិក | 2019<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) | 2018<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) |
|---|---|---|---|---|
| ប្រាក់បៀវត្សរ៍ និង អត្ថប្រយោជន៍ | 197,376 | 188,174 | 799,768 | 761,164 |
| កម្រៃសម្រាប់ក្រុមប្រឹក្សាភិបាល | 53,000 | 50,600 | 214,756 | 204,677 |
| | 250,376 | 238,774 | 1,014,524 | 965,841 |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

## 23. សម្ព័ន្ធញាតិ (ត)

### ខ. ប្រតិបត្តិការនិងសមតុល្យជាមួយសម្ព័ន្ធញាតិ (ត)

### *(iii) សមតុល្យជាមួយសម្ព័ន្ធញាតិ*

| | 2019<br>ដុល្លារអាមេរិក | 2018<br>ដុល្លារអាមេរិក | 2019<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) | 2018<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) |
|---|---|---|---|---|
| ឥណទានផ្តល់ដល់សម្ព័ន្ធញាតិ<br>(កំណត់សម្គាល់ 9) | 685,460 | 608,386 | 2,793,250 | 2,444,495 |
| បុរេប្រទានទៅម្ចាស់ភាគហ៊ុន<br>(កំណត់សម្គាល់ 10) | 70,500 | 60,300 | 287,288 | 242,285 |
| ប្រាក់កម្ចី (កំណត់សម្គាល់ 13) | 302,000 | 302,000 | 1,230,650 | 1,213,436 |

## 24. កិច្ចសន្យា និងយថាភាព

### ក. កិច្ចសន្យាភតិសន្យាប្រតិបត្តិការ

ក្រុមហ៊ុនមានភតិសន្យាប្រតិបត្តិការ ទៅលើការជួលការិយាល័យកណ្តាល និងសាខាដែលការចំណាយលើថ្លៃជួលអប្បបរមាមានដូចខាងក្រោម៖

| | នាថ្ងៃទី 31 ខែ ធ្នូ | | នាថ្ងៃទី 31 ខែ ធ្នូ | |
|---|---|---|---|---|
| | ឆ្នាំ 2019<br>ដុល្លារអាមេរិក | ឆ្នាំ 2018<br>ដុល្លារអាមេរិក | ឆ្នាំ 2019<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) | ឆ្នាំ 2018<br>ពាន់រៀល<br>(កំណត់សម្គាល់ 5) |
| តិចជាង 1 ឆ្នាំ | 91,302 | 70,389 | 372,056 | 282,823 |
| 1 ទៅ 5 ឆ្នាំ | 41,305 | 32,167 | 168,318 | 129,247 |
| | 132,607 | 102,556 | 540,374 | 412,070 |

# ធនាគារពលរដ្ឋរុងរឿង អិលធីឌី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

## 24. កិច្ចសន្យា និងយថាភាព (ត)

### ខ. យថាភាពលើពន្ធ

ប្រព័ន្ធពន្ធដារនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានលក្ខណៈថ្មី ហើយពន្ធទាំងនេះតែងតែមានការផ្លាស់ប្តូរ ជាញឹកញាប់ហើយតែងតែមានភាពមិនច្បាស់លាស់ ភាពផ្ទុយគ្នានិងស្ថិតនៅក្រោមបំណកស្រាយបំភ្លឺ ។ ជាទូទៅ តែងតែកើតឡើងនូវភាពខុសគ្នាចំពោះការបកស្រាយបំភ្លឺក្នុងចំណោមអាជ្ញាធរពន្ធដារ និង យុត្តាធិការ ។ ពន្ធត្រូវស្ថិតក្រោមការត្រួតពិនិត្យ និងធ្វើការតាមដានអង្កេត ដោយក្រុមអាជ្ញាធរ ជាច្រើនដែលអាចផ្តល់នូវលទ្ធភាពតាមច្បាប់ក្នុងការដាក់ពិន័យ ដាក់ទណ្ឌកម្ម និងបង់ការប្រាក់ ។

បញ្ហាទាំងនេះ អាចបង្កើតឲ្យមានហានិភ័យពន្ធ នៅក្នុងព្រះរាជាណាចក្រកម្ពុជាមានលក្ខណៈធំជាងនៅប្រទេសដទៃទៀត ។ អ្នកគ្រប់គ្រងជឿជាក់ថា ការធ្វើសំវិធានធនមានលក្ខណៈគ្រប់គ្រាន់ដោយផ្អែកទៅ លើការបកស្រាយនៃនីតិកម្មពន្ធ ។ ក៏ប៉ុន្តែអាជ្ញាធរជាប់ពាក់ព័ន្ធ អាចនឹងមានបំណកស្រាយខុសគ្នា ហើយផលប៉ះពាល់អាចមានទំហំធំ ។

## 25. តម្លៃសមស្របនៃទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ

តម្លៃសមស្រប សំដៅទៅលើតម្លៃដែលទ្រព្យសកម្មអាចត្រូវបានដោះដូរ ឬបំណុលអាចត្រូវបានទូទាត់តាមមូលដ្ឋានធម្មតា ។ ដោយសារតម្លៃសមស្របដែលអាចផ្ទៀងផ្ទាត់បាន មិនអាចរកបាន ដូច្នេះ តម្លៃសមស្របសម្រាប់ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុមួយភាគធំ មិនអាចរកបានទេ ។ ហេតុនេះ តម្លៃសមស្រប ផ្អែកលើការសន្មតរបស់អ្នកគ្រប់គ្រងដោយយោងតាមប្រភេទនៃទ្រព្យសកម្ម និងបំណុលទាំងនោះ។ តាមមតិយោបល់របស់អ្នកគ្រប់គ្រង តម្លៃយោងនៃទ្រព្យសកម្ម និងបំណុល ដែលបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ មានតម្លៃប្រហាក់ប្រហែល នឹងតម្លៃសមស្រប ។

## 26. គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗ ដែលបានបង្ហាញនៅខាងក្រោមនេះ ត្រូវបានអនុវត្តដោយសង្គតិភាព នៅគ្រប់ការិយបរិច្ឆេទ ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ និងនៅក្នុងការរៀបចំរបាយការណ៍ស្ថានហិរញ្ញវត្ថុនៅថ្ងៃទី1 ខែ មករា ឆ្នាំ 2018 សម្រាប់គោលបំណងអន្តរកាលទៅកេ ស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធនតូច និងមធ្យម លើកលែងតែមានការបង្ហាញផ្សេងពីនេះ ។

### (ក) មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើងទៅតាមមូលដ្ឋានថ្លៃដើមដំបូង ។

## 26. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ខ) ប្រតិបត្តិការជារូបិយប័ណ្ណបរទេស

សកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ ។

ទ្រព្យសកម្មនិងបំណុលរូបិយវត្ថុនាកាលបរិច្ឆេទរាយការណ៍ដែលជារូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិកដោយប្រើអត្រានាកាលបរិច្ឆេទរាយការណ៍ ។ ភាពលម្អៀងពីការប្តូររូបិយប័ណ្ណបរទេសត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត ។ ធាតុមិនមែនរូបិយវត្ថុ ត្រូវបានវាស់វែងផ្អែកលើមូលដ្ឋានថ្លៃដើមដំបូង ដែលជារូបិយប័ណ្ណបរទេសផ្សេងទៀត ត្រូវបានប្តូរដោយប្រើអត្រាប្តូរប្រាក់នៅកាលបរិច្ឆេទនៃប្រតិបត្តិការដំបូង។

### (គ) ការប្រាក់

ចំណូលការប្រាក់ និងចំណាយការប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព ។ "អត្រាការប្រាក់ប្រសិទ្ធភាព" គឺជាអត្រាដែលអាចធ្វើអប្បហារសាច់ប្រាក់ដែលរំពឹងថានឹងទូទាត់ ឬនឹងត្រូវទទួល តាមរយៈអាយុកាលរំពឹងទុករបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ (ឬ ក្នុងករណីណាមួយ ដែលមានរយៈពេលខ្លី) តាមតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុនោះ ។

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាព ក្រុមហ៊ុនធ្វើការប៉ាន់ស្មានលើលំហូរទឹកប្រាក់នាពេលអនាគតដោយពិចារណារាល់លក្ខខណ្ឌទាំងអស់របស់កិច្ចសន្យាហិរញ្ញវត្ថុ ប៉ុន្តែមិនរាប់បញ្ចូលនូវការរំពឹងទុកលើការខាតបង់ឥណទាននោះទេ ។

ការគណនាអត្រាការប្រាក់ប្រសិទ្ធភាព រួមបញ្ចូលនូវថ្លៃដើមប្រតិបត្តិការ និងកម្រៃទាំងអស់ដែលបានបង់ ឬទទួល ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព ។ ថ្លៃដើមប្រតិបត្តិការរួមមាន ការចំណាយបន្ថែមដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការទិញ ឬការបោះផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ។

### (ឃ) កម្រៃ និងជើងសារ

ចំណូល និងចំណាយកម្រៃ និងជើងសារ ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព របស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានរួមបញ្ចូលទៅក្នុងអត្រាការប្រាក់ប្រសិទ្ធភាព ។

ចំណូលកម្រៃ និងជើងសារផ្សេងទៀត ត្រូវបានទទួលស្គាល់នៅពេលបានបំពេញសេវាកម្ម ។ ប្រសិនបើឥណទានជាប់កិច្ចសន្យាមិនត្រូវបានគេរំពឹងថានឹងមានលទ្ធផលក្នុងការដកប្រាក់ឥណទាននោះ នៅពេលដែលតម្លៃកិច្ចសន្យាឥណទានភាគីពាក់ព័ន្ធ ត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានថេរក្នុងការិយបរិច្ឆេទកិច្ចសន្យា ។ ចំណាយកម្រៃផ្សេងៗ និងជើងសារពាក់ព័ន្ធយ៉ាងពិតប្រាកដទៅលើប្រតិបត្តិការ នឹងថ្លៃសេវាកម្មដែលត្រូវបានចំណាយនៅពេលសេវាកម្មត្រូវបានទទួល ។

# ធនាគារពាណិជ្ជកម្ម អ៊ែលធីធី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

## 26. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ង) ភតិសន្យា

ការទូទាត់លើភតិសន្យាត្រូវទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាតតាមមូលដ្ឋានដករំលោះថេរក្នុងអំឡុងពេលនៃភតិសន្យា ។ ការលើកទឹកចិត្តភតិសន្យាដែលបានទទួល ត្រូវទទួលស្គាល់ជាការរួមបញ្ចូលផ្នែកនៃការចំណាយភតិសន្យាសរុបក្នុងអំឡុងពេលនៃភតិសន្យា ។

### (ច) ពន្ធលើប្រាក់ចំណេញ

ចំណាយពន្ធលើប្រាក់ចំណេញរួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ ។ វាត្រូវបានទទួលស្គាល់ជាចំណេញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផលលម្អិត លើកលែងតែធាតុណាបានទទួលស្គាល់ដោយផ្ទាល់ក្នុងមូលធន ឬនៅក្នុងរបាយការណ៍លម្អិតផ្សេងៗទៀត ។

#### *(i) ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ*

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ រួមមានពន្ធដែលត្រូវបង់ឬទទួល លើប្រាក់ចំណេញ ឬខាតជាប់ពន្ធប្រចាំឆ្នាំនិងនិយ័តភាពទាំងឡាយទៅលើពន្ធត្រូវបង់ ឬត្រូវទទួលពីការិយបរិច្ឆេទមុន ។ ចំនួនពន្ធលើប្រាក់ចំណេញដែលត្រូវបង់ ឬត្រូវទទួល គឺជាការប៉ាន់ស្មានដ៏ល្អបំផុតនៃចំនួនពន្ធដែលរំពឹងថានឹងត្រូវទូទាត់ ឬបានទទួលដែលបានបញ្ជាក់ពីភាពមិនប្រាកដប្រជាទាក់ទងនឹងពន្ធលើប្រាក់ចំណូល ប្រសិនបើមាន ។ ការវាស់វែងដោយប្រើប្រាស់អត្រាពន្ធដែលបានអនុម័តជាធរមាននៅកាលបរិច្ឆេទនៃរបាយការណ៍ ។

#### *(ii) ពន្ធពន្យារ*

ពន្ធពន្យារត្រូវបានទទួលស្គាល់ដោយផ្អែកលើភាពលម្អៀងបណ្តោះអាសន្ន រវាងតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងសម្រាប់ការគិតពន្ធ ។

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវទទួលស្គាល់ចំពោះការខាតបង់ពន្ធមិនទាន់បានប្រើប្រាស់ឥណទានពន្ធ និងភាពលម្អៀងបណ្តោះអាសន្នដែលអាចកាត់កងបាន ត្រឹមកម្រិតដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតអាចប្រើប្រាស់សម្រាប់កាត់កងជាមួយភាពលម្អៀងបណ្តោះអាសន្ននោះបាន ។ ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ និងត្រូវបានកាត់បន្ថយក្នុងករណីមិនអាចប្រើប្រាស់នូវអត្ថប្រយោជន៍ពន្ធទាំងនោះបាន ។

ពន្ធពន្យារជាទ្រព្យសកម្មដែលមិនទទួលស្គាល់ ត្រូវបានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ហើយត្រូវបានកត់ត្រាក្នុងចំនួនដែលអាចនឹងមានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតអាចប្រើបាន ។

ពន្ធពន្យារជាទ្រព្យសកម្មត្រូវវាស់វែងតាមអត្រាពន្ធ ដែលរំពឹងថានឹងត្រូវប្រើចំពោះភាពលម្អៀងបណ្តោះអាសន្ននៅពេលដែលវាអាចប្រើប្រាស់បាន ឬកាត់កងបាន ដោយប្រើអត្រាពន្ធនៅកាលបរិច្ឆេទរាយការណ៍ ។

## 26. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ច) ពន្ធលើប្រាក់ចំណេញ (ត)

*(ii) ពន្ធពន្យារ (ត)*

ការវាស់វែងពន្ធពន្យារជាទ្រព្យសកម្មឆ្លុះបញ្ចាំងនូវពន្ធដែលក្រុមហ៊ុនរំពឹងនៅកាលបរិច្ឆេទរាយការណ៍ថា អាចប្រើប្រាស់បាន ឬអាចកាត់កងបាននូវតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល ។

### (ឆ) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

*(i) ការទទួលស្គាល់*

ក្រុមហ៊ុនទទួលស្គាល់ជាលើកដំបូងលើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុនៅពេលដែលក្រុមហ៊ុនក្លាយជាភាគីកិច្ចសន្យា ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប បូកនឹងថ្លៃដើមប្រតិបត្តិការដែលកើតមកពីការទិញ ឬលក់ ទ្រព្យ និងបំណុលទាំងនោះ ។

*(ii) ការចាត់ចំណាត់ថ្នាក់*

ក្រុមហ៊ុនចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ជាឧបករណ៍ហិរញ្ញវត្ថុជាមូលដ្ឋាន ស្របទៅតាមផ្នែកទី 11 *ឧបករណ៍ហិរញ្ញវត្ថុជាមូលដ្ឋាន* ។

*(iii) ការឈប់ទទួលស្គាល់*

ក្រុមហ៊ុនឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិក្នុងកិច្ចសន្យាក្នុងការទទួលលំហូរទឹកប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុផុតកំណត់ ឬបានទូទាត់ ឬការផ្ទេរសិទ្ធិទទួលលំហូរទឹកប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការដែលហានិភ័យទាំងអស់ និងភាពជាកម្មសិទ្ធិនៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានផ្ទេរ ឬក្នុងករណីដែលក្រុមហ៊ុនមិនផ្ទេរ ឬមិនរក្សាទុកនូវរាល់ហានិភ័យ និងភាពជាកម្មសិទ្ធិ ហើយវាមិនរក្សាការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ ។

ក្រុមហ៊ុនឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលកាតព្វកិច្ចក្រោមកិច្ចសន្យាត្រូវបានរំលាយ ឬលុបចោល ឬផុតអាណត្តិ ។

*(iv) ការកាត់កង*

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ អាចត្រូវកាត់កងគ្នាបាន និងត្រូវបង្ហាញជាចំនួនសុទ្ធនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ លុះត្រាតែក្រុមហ៊ុនមានសិទ្ធិតាមច្បាប់ដើម្បីធ្វើការកាត់កងគ្នាបាន និងមានបំណងធ្វើការទូទាត់ដោយផ្អែកលើមូលដ្ឋានចំនួននៅសល់សុទ្ធ ឬក៏ទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា ។

# ធនាគារពាណិជ្ជកម្មរដ្ឋ ហ៊ីលធ៊ីអ៊ី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

## 26. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឆ) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(v) ការវាស់វែងតាមរំលស់ថ្លៃដើម*

រំលស់ថ្លៃដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ គឺជាចំនួនទឹកប្រាក់ដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងនៅពេលទទួលស្គាល់ជាលើកដំបូង ដកការទូទាត់ប្រាក់ដើម និងបូក ឬដករំលស់បង្គរដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៃភាពខុសគ្នារវាងចំនួនទឹកប្រាក់ ដែលបានទទួលស្គាល់ដំបូង និងចំនួនទឹកប្រាក់ដល់កាលកំណត់ដកឱនភាពនៃតម្លៃ ។

*(vi) ការវាស់វែងតម្លៃសមស្រប*

តម្លៃសមស្រប គឺជាតម្លៃដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្ម ឬតម្លៃដែលបានទូទាត់ចំពោះការផ្ទេរបំណុលនៅក្នុងប្រតិបត្តិការធម្មតា រវាងអ្នកចូលរួមក្នុងទីផ្សារ នាកាលបរិច្ឆេទនៃការវាស់វែងនៅក្នុងទីផ្សារគោល ឬក្នុងករណីមិនមានទីផ្សារគោល គឺយកទីផ្សារដែលមានអត្ថប្រយោជន៍បំផុត ដែលក្រុមហ៊ុនអាចកំណត់រកបាននៅកាលបរិច្ឆេទនៃការវាស់វែងនោះ ។ តម្លៃសមស្របរបស់បំណុល ឆ្លុះបញ្ចាំងពីហានិភ័យនៃការមិនអនុវត្តកាតព្វកិច្ច ។

ក្រុមហ៊ុនវាស់វែងតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ ដោយប្រើសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មរបស់ឧបករណ៍នោះ ប្រសិនបើមាន ។ ទីផ្សារមួយចាត់ទុកជាទីផ្សារសកម្ម ប្រសិនបើប្រតិបត្តិការរបស់ទ្រព្យសកម្ម ឬបំណុល កើតឡើងញឹកញាប់ ហើយទំហំប្រតិបត្តិការមានភាពគ្រប់គ្រាន់ក្នុងការផ្តល់ព័ត៌មានតម្លៃជាទៀងទាត់ ។

ប្រសិនបើពុំមានសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មទេ នោះក្រុមហ៊ុនត្រូវប្រើបច្ចេកទេសវាយតម្លៃណាដែលអាចប្រើប្រាស់ទិន្នន័យដែលអាចអង្កេតបានជាអតិបរមា និងកាត់បន្ថយនូវការប្រើប្រាស់ទិន្នន័យដែលមិនអាចអង្កេតបាន ។ បច្ចេកទេសវាយតម្លៃដែលបានជ្រើសរើស ត្រូវរួមបញ្ចូលនូវកត្តាទាំងអស់ដែលអ្នកចូលរួមក្នុងទីផ្សារនឹងពិចារណានៅក្នុងការកំណត់តម្លៃ ។

ភស្តុតាងដ៏ល្អបំផុតសម្រាប់តម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ នៅពេលទទួលស្គាល់ជាលើកដំបូងជាទូទៅគឺជាតម្លៃប្រតិបត្តិការ មានន័យថា ជាតម្លៃសមស្របនៃផលតបស្នងបានផ្តល់ឲ្យ ឬបានទទួល ។ ប្រសិនបើក្រុមហ៊ុនកំណត់ថា តម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង ខុសពីតម្លៃប្រតិបត្តិការ ហើយតម្លៃសមស្របនេះពុំមានភស្តុតាងមកបញ្ជាក់ តាមរយៈសម្រង់តម្លៃក្នុងទីផ្សារសកម្មចំពោះទ្រព្យសកម្ម ឬបំណុលដែលស្រដៀងគ្នា ឬក៏តាមរយៈបច្ចេកទេសវាយតម្លៃ ដោយប្រើប្រាស់ទិន្នន័យទីផ្សារដែលអាចអង្កេតបាន ត្រូវបានសន្មតថាមិនសារវន្ត ដូច្នេះឧបករណ៍ហិរញ្ញវត្ថុត្រូវវាស់វែងជាលើកដំបូងតាមតម្លៃសមស្របដោយកែតម្រូវតាមរយៈការពន្យារនូវភាពខុសគ្នារវាងតម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង និងតម្លៃប្រតិបត្តិការ ។

## 26. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ធ) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vi) ការវាស់វែងតម្លៃសមស្រប (ត)*

បន្ទាប់មកទៀត ភាពខុសគ្នានោះគឺត្រូវទទួលស្គាល់ជាចំណេញ ឬខាត ផ្អែកលើអាយុកាលរបស់ឧបករណ៍នោះ ក៏ប៉ុន្តែមិនឲ្យយូរជាងការវាយតម្លៃតាមរយៈទិន្នន័យទីផ្សារ ដែលអាចអង្កេតបានឬនៅពេលបញ្ចប់ប្រតិបត្តិការនោះទេ ។

ក្រុមហ៊ុនទទួលស្គាល់ការផ្ទេររវាងកម្រិតនៃឋានានុក្រមតម្លៃសមស្រប នៅចុងការិយបរិច្ឆេទនៃរបាយការណ៍អំឡុងពេលដែលការផ្លាស់ប្តូរបានកើតឡើង ។

*(vii) ការកំណត់អត្តសញ្ញាណ និងការវាស់វែងលើឱនភាពនៃតម្លៃ*

*ភស្តុតាងដែលបញ្ជាក់ថាមានឱនភាពនៃតម្លៃ*

នៅកាលបរិច្ឆេទរបាយការណ៍នីមួយៗ ក្រុមហ៊ុនបានវាយតម្លៃថាតើមានភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកត់ត្រាតាមថ្លៃដើម ឬទេ ។ ទ្រព្យសកម្មហិរញ្ញវត្ថុ ឬក្រុមទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃ នៅពេលដែលភស្តុតាងបញ្ជាក់ថា មានការខាតបង់ព្រឹត្តិការណ៍មួយ ឬច្រើនបានកើតឡើងបន្ទាប់ពីការទទួលស្គាល់ទ្រព្យសកម្មលើកដំបូង ហើយដែលនាំឲ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅលើលំហូរទឹកប្រាក់នាពេលអនាគតនៃទ្រព្យសកម្មដែលអាចប៉ាន់ស្មានដោយភាពជឿជាក់បាន ។

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពនៃតម្លៃរួមមាន៖

- ការលំបាកផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំងរបស់អតិថិជន ឬអ្នកបោះផ្សាយ
- ការខកខានមិនបានសង ឬហួសកាលកំណត់របស់អតិថិជន
- ការរៀបចំឡើងវិញលើលក្ខខណ្ឌទូទាត់សង ដែលក្រុមហ៊ុនមិនបានរំពឹងទុក
- សញ្ញាណដែលបញ្ជាក់ថាអតិថិជន ឬអ្នកបោះផ្សាយទំនងនឹងជួបប្រទះការក្ស័យធន
- ការបាត់បង់ទីផ្សារសកម្ម សម្រាប់ទ្រព្យបញ្ចាំ ឬ
- ទិន្នន័យដែលអាចអង្កេតបានពាក់ព័ន្ធនឹងក្រុមនៃទ្រព្យសកម្ម ដូចជាការផ្លាស់ប្តូរអវិជ្ជមាននៃស្ថានភាពនៃការទូទាត់របស់អ្នកខ្ចី ឬអ្នកបោះផ្សាយជាក្រុម ឬលក្ខខណ្ឌសេដ្ឋកិច្ចដែលទាក់ទងនឹងការខកខានមិនបានសងជាក្រុម ។

# ឥណទានពលរដ្ឋរុងរឿង អិលធីឌី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

## 26. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឆ) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii) ការកំណត់អត្តសញ្ញាណ និងការវាស់វែងលើឱនភាពនៃតម្លៃ (ត)*

*ការវាយតម្លៃជាលក្ខណៈទោល និងជាក្រុម*

រាល់ទ្រព្យសកម្មសារវន្ត ត្រូវបានវាយតម្លៃជាលក្ខណៈទោល ។ សម្រាប់ឱនភាពនៃតម្លៃ ការវាយតម្លៃជាលក្ខណៈទោលដែលត្រូវបានរកឃើញថាមិនមានឱនភាពនៃតម្លៃ ជាពិសេសត្រូវបានវាយតម្លៃជាក្រុមសម្រាប់ឱនភាពនៃតម្លៃដែលបានកើតឡើង ប៉ុន្តែមិនទាន់កើតឡើងនៅឡើយទេ ។

សមាសធាតុទោលនៃសំវិធានធនសរុបសម្រាប់ឱនភាពនៃតម្លៃ ត្រូវបានអនុវត្តចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលបានវាយតម្លៃជាលក្ខណៈទោលនៃឱនភាពនៃតម្លៃ ហើយត្រូវបានរកឃើញថាមានឱនភាពនៃតម្លៃទោល និងផ្អែកតាមការប៉ាន់ស្មានដ៏ប្រសើរបំផុតរបស់អ្នកគ្រប់គ្រង លើតម្លៃបច្ចុប្បន្ននៃលំហូរទឹកប្រាក់ដែលរំពឹងថានឹងទទួលបាន ។ ក្នុងការប៉ាន់ស្មានលំហូរទឹកប្រាក់ទាំងនេះ អ្នកគ្រប់គ្រងធ្វើការវិនិច្ឆ័យអំពីស្ថានភាពហិរញ្ញវត្ថុរបស់កូនបំណុល និងតម្លៃសុទ្ធដែលអាចលក់បានចំពោះទ្រព្យបញ្ចាំណាមួយ ។ ទ្រព្យសកម្មដែលមានឱនភាពនៃតម្លៃនីមួយៗ ត្រូវបានវាយតម្លៃលើគុណសម្បត្តិរបស់វា ហើយយុទ្ធសាស្ត្រគណនា និងការប៉ាន់ស្មានលំហូរទឹកប្រាក់ដែលអាចប្រមូលបានមកវិញ ត្រូវបានអនុម័តឯករាជ្យដោយអ្នកគ្រប់គ្រង ។

សមាសធាតុរួមនៃឱនភាពនៃតម្លៃត្រូវបានបង្កើតឡើងសម្រាប់៖

- ជាក្រុមនៃឥណទានត្រូវទទួល មានលក្ខណៈដូចគ្នា ដែលមិនត្រូវបានចាត់ទុកថាជាលក្ខណៈទោលសារវន្ត និង
- ក្រុមនៃទ្រព្យសកម្មដែលមានលក្ខណៈទោលជាសារវន្ត ប៉ុន្តែមិនត្រូវបានរកឃើញថាមានឱនភាពនៃតម្លៃទោលនោះ ។

សំវិធានធនជាក្រុម សម្រាប់ក្រុមនៃឥណទានមានលក្ខណៈដូចគ្នា ត្រូវបានបង្កើតឡើងដោយប្រើប្រាស់វិធីសាស្ត្រស្ថិតិ ដូចជាវិធីសាស្ត្រអត្រាវិល ឬសម្រាប់ផលប័ត្រតូចៗ ដែលមិនមានព័ត៌មានគ្រប់គ្រាន់វិធីសាស្ត្រផ្អែកលើបទពិសោធន៍អត្រាបាត់បង់ប្រវត្តិសាស្ត្រ ។

ក្នុងការវាយតម្លៃសំវិធានធនលើខាតបង់ជាក្រុម អ្នកគ្រប់គ្រងបានពិចារណាលើកត្តាមួយចំនួនដូចជា គុណភាពឥណទាន ទំហំផលប័ត្រ ការប្រមូលផ្តុំ និងកត្តាសេដ្ឋកិច្ចជាដើម ។ ដើម្បីប៉ាន់ប្រមាណនូវតម្រូវការសំវិធានធន ការសន្មតត្រូវបានធ្វើឡើងដើម្បីកំណត់ពីលក្ខណៈនៃការខាតបង់ ដែលត្រូវបានយកគំរូតាម និងការកំណត់ទិន្នន័យប៉ារ៉ាម៉ែត្រតាមតម្រូវការ ដោយផ្អែកលើបទពិសោធន៍ប្រវត្តិសាស្ត្រ និងស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន ។ ភាពត្រឹមត្រូវនៃសំវិធានធន អាស្រ័យលើការសន្មតគំរូ និងប៉ារ៉ាម៉ែត្រដែលត្រូវបានប្រើក្នុងការកំណត់សំវិធានធនជាក្រុម ។

# ឥណទានពលរដ្ឋរុងរឿង អិលធីឌី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

## 26. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឆ) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii) ការកំណត់អត្តសញ្ញាណ និងការវាស់វែងលើឱនភាពនៃតម្លៃ (ត)*

*ការវាស់វែង*

ការខាតបង់លើឱនភាពនៃតម្លៃទៅលើទ្រព្យសកម្ម ដែលត្រូវបានវាស់វែងតាមរំលស់ថ្លៃដើមត្រូវបានគណនាដោយភាពខុសគ្នារវាងតម្លៃយោង និងតម្លៃបច្ចុប្បន្ននៃលំហូរទឹកប្រាក់ដែលបានប៉ាន់ស្មាននាពេលអនាគតដែលត្រូវបានធ្វើអប្បហារតាមអត្រាការប្រាក់ប្រសិទ្ធភាពដំបូងរបស់ទ្រព្យសកម្ម ។

*ការទទួលបានមកវិញ និងការលុបចោលឱនភាពនៃតម្លៃ*

ប្រសិនបើក្នុងការិយបរិច្ឆេទបន្ទាប់ ចំនួនឱនភាពនៃតម្លៃមានការថយចុះ ហើយការថយចុះអាចទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលកើតឡើង បន្ទាប់ពីឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់ ក្រុមហ៊ុនត្រូវធ្វើការកែប្រែលើការខាតបង់ឱនភាពនៃតម្លៃ ដែលបានទទួលស្គាល់ពីមុនដោយផ្ទាល់ ឬការធ្វើនិយ័តភាពចំពោះគណនីសំវិធានធន ។

ការទទួលបានមកវិញនូវឱនភាពនៃតម្លៃនឹងមិនបណ្តាលឲ្យមានតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ (គណនីសំវិធានធន) លើសពីចំនួនតម្លៃយោងដែលមានឱនភាពនៃតម្លៃដែលមិនបានទទួលស្គាល់ពីមុននោះទេ ។ ក្រុមហ៊ុនត្រូវទទួលស្គាល់ចំនួនទឹកប្រាក់ដែលទទួលបានមកវិញជាចំណេញ ឬខាតភ្លាមៗ ។

ក្រុមហ៊ុនធ្វើការលុបចោលឥណទាន ឬការវិនិយោគលើមូលបត្របំណុល ដោយផ្នែក ឬក៏ទាំងស្រុង និងសំវិធានធនលើឱនភាពនៃតម្លៃ នៅពេលដែលអ្នកគ្រប់គ្រងកំណត់ថាមិនមានលទ្ធភាពជាក់លាក់ក្នុងការប្រមូលបានមកវិញ ។

### (ជ) សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ក្នុងដៃ និងសមតុល្យសាច់ប្រាក់ក្នុងធនាគារ ប្រាក់បញ្ញើ និងការវិនិយោគរយៈពេលខ្លី ដែលមានកាលវសាន្តនៅពេលតម្កល់ដំបូងមានរយៈពេល 3 ខែ ឬតិចជាង ដែលអាចប្តូរជាសាច់ប្រាក់ពេលណាក៏បាន ដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃហើយត្រូវបានប្រើដោយក្រុមហ៊ុនក្នុងការគ្រប់គ្រងកិច្ចសន្យារយៈពេលខ្លី ។

សាច់ប្រាក់ និងសាច់ប្រាក់សមមូលត្រូវបានគិតតាមរំលស់ថ្លៃដើមតាមរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ។

## ឥណទានពលរដ្ឋរុងរឿង អិលធីឌី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

### 26. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

#### (ឈ) ប្រាក់តម្កល់តាមច្បាប់

ប្រាក់តម្កល់តាមច្បាប់ ត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជា ស្របតាមច្បាប់ស្តីពី គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានកំណត់ជាភាគរយនៃដើមទុនអប្បបរមារបស់ក្រុមហ៊ុន ដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា ។ ប្រាក់តម្កល់តាមច្បាប់ មិនអាចយកមកប្រើប្រាស់ជាហិរញ្ញប្បទានសម្រាប់ប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុនឡើយ ដូច្នេះវាមិនត្រូវបានចាត់ទុកថាជាផ្នែកមួយនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល នៅក្នុងរបាយការណ៍លំហូរទឹកប្រាក់ឡើយ ។

#### (ញ) ឥណទានផ្តល់ដល់អតិថិជន

ឥណទានផ្តល់ដល់អតិថិជន គឺជាទ្រព្យសកម្មហិរញ្ញវត្ថុអនិស្សន្ទដែលទូទាត់ប្រាក់ដែលមានកាលកំណត់ ឬកំណត់ដែលមិនត្រូវបានដកស្រង់នៅលើទីផ្សារសកម្ម ហើយក្រុមហ៊ុនមិនមានបំណងលក់ភ្លាមៗ ឬក្នុងរយៈពេលខ្លីនោះទេ ។

ឥណទានផ្តល់ដល់អតិថិជន ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្របបូករួមនឹងការចំណាយប្រតិបត្តិការដោយផ្ទាល់បន្ថែមហើយត្រូវបានវាស់វែងជាបន្តបន្ទាប់ដោយចំណាយរំលស់ ដោយប្រើវិធីសាស្ត្រការប្រាក់ប្រកបដោយប្រសិទ្ធភាព ។

#### (ដ) ទ្រព្យសកម្មផ្សេងទៀត

ទ្រព្យសកម្មផ្សេងៗ ត្រូវបានកត់ត្រាតាមតម្លៃរំលស់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រកបដោយប្រសិទ្ធភាពក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

#### (ឋ) ទ្រព្យ និងបរិក្ខារ

(i) ធាតុនៃទ្រព្យ និងបរិក្ខារត្រូវបានវាស់វែងដោយថ្លៃដើមដកចំណាយរំលស់និងដកការខាតបង់លើឱនភាពនៃតម្លៃបង្គរប្រសិនបើមាន ។ នៅពេលធាតុនៃទ្រព្យ និងបរិក្ខារមានអាយុកាលមានប្រយោជន៍ផ្សេងៗគ្នា ពួកគេត្រូវបានកត់ត្រាទុកថាជារបស់ដាច់ដោយឡែកពីគ្នា (សមាសធាតុសំខាន់ៗ)នៃទ្រព្យ និងបរិក្ខារ ។

# ឥណទានពលរដ្ឋរុងរឿង អិលធីឌី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

## 26. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឋ) ទ្រព្យ និងបរិក្ខារ (ត)

(ii) រំលស់លើទ្រព្យ និងបរិក្ខារ ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងចំណេញ ឬខាតតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យ និងបរិក្ខារនីមួយៗតាមវិធីសាស្ត្ររំលស់ថេរ ដូចខាងក្រោម៖

| | |
|---|---|
| ការកែលំអអគារ | 4 ឆ្នាំ |
| យានយន្ត | 5 ឆ្នាំ |
| គ្រឿងសង្ហារឹមនិងគ្រឿងបំពាក់ | 4 ឆ្នាំ |
| កុំព្យូទ័រ និងបរិក្ខារការិយាល័យ | 4 ឆ្នាំ |

(iii) ការចំណាយបន្ទាប់ដែលពាក់ព័ន្ធទៅនឹងផ្នែកមួយនៃទ្រព្យ និងបរិក្ខារ ដែលបានទទួលស្គាល់រួចមកហើយ ត្រូវបានបូកបញ្ចូលទៅក្នុងតម្លៃយោងនៃផ្នែកនោះ ប្រសិនបើ អាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដល់ក្រុមហ៊ុនលើសពីស្តង់ដារដើម ។ រាល់ការចំណាយបន្ទាប់ផ្សេងៗទៀត ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងការិយបរិច្ឆេទដែលបានកើតឡើង ។

(iv) ចំណេញ ឬខាតពីការឈប់ប្រើ ឬការលក់ចេញផ្នែកនៃទ្រព្យ និងបរិក្ខារណាមួយត្រូវបានកំណត់ដោយភាពខុសគ្នារវាងសាច់ប្រាក់ទទួលបានពីការលក់ និងតម្លៃយោងនៃផ្នែកនោះ ហើយត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលនាថ្ងៃឈប់ប្រើ ឬលក់ចេញ ។

(v) ទ្រព្យ និងបរិក្ខារ ដែលបានដករំលស់អស់ហើយត្រូវបានរក្សាទុកក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូតដល់ថ្ងៃដែលទ្រព្យ និងបរិក្ខារទាំងនោះត្រូវបានលក់ចេញ ឬលុបបំបាត់ចោល ។

### (ឌ) ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី រួមមានសូហ្វវែរដែលរួមបញ្ចូលទាំងថ្លៃដើមក្នុងការទិញ និងដំឡើងសូហ្វវែរ ដែលមិនមែនជាជាធាតុនៃផ្នែករឹង ហើយត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរ ប្រសិនបើមាន ។ ថ្លៃដើមសូហ្វវែរ ត្រូវបានដករំលស់ទៅតាមការប៉ាន់ស្មានអាយុកាលប្រើប្រាស់ 4 ឆ្នាំ តាមវិធីសាស្ត្ររំលស់ថេរ ។

ការចំណាយដែលបានកើតឡើងនៅក្នុងការធ្វើផែនការឬវាយតម្លៃសំណើរសូហ្វវែរ ឬក្នុងការថែរក្សាប្រព័ន្ធបន្ទាប់ពីដាក់ឲ្យប្រើប្រាស់ មិនមែនមូលធនីយកម្ម ។

# ធនាគារពលរដ្ឋរុងរឿង អិលធីឌី

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

### 26. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

#### (ឈ) ឱនភាពនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានត្រួតពិនិត្យឡើងវិញនៅរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានសញ្ញាណណាមួយដែលបង្ហាញថាទ្រព្យសកម្មទាំងនោះមានឱនភាពនៃតម្លៃ ។ ប្រសិនបើមានសញ្ញាណនោះកើតឡើង ការប៉ាន់ស្មានលើតម្លៃដែលអាចប្រមូលបានមកវិញរបស់ទ្រព្យសកម្មត្រូវបានធ្វើឡើង ។

ដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺជាតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃសមស្រប ដកចំណាយដើម្បីលក់ចេញ ។ ក្នុងការប៉ាន់ប្រមាណតម្លៃប្រើប្រាស់សាច់ប្រាក់រំពឹងថានឹងទទួលបាននាពេលអនាគត ត្រូវបានធ្វើអប្បហារទៅតម្លៃបច្ចុប្បន្នដោយប្រើអត្រាការប្រាក់មុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងការប៉ាន់ប្រមាណតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ សម្រាប់ទ្រព្យសកម្មទាំងនោះ ។ សម្រាប់គោលបំណងនៃការត្រួតពិនិត្យលើឱនភាពនៃតម្លៃទ្រព្យសកម្ម ត្រូវបានដាក់បញ្ចូលគ្នាជាក្រុម ដែលអាចបង្កើតសាច់ប្រាក់បានតូចបំផុតពីការបន្តការប្រើប្រាស់ដោយមិនពឹងផ្អែកខ្លាំងលើលំហូរទឹកប្រាក់នៃទ្រព្យសកម្មដទៃទៀត ឬក្រុមទ្រព្យសកម្មដទៃទៀតហៅកាត់ថា ("ឯកតាបង្កើតសាច់ប្រាក់") ។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងរបស់ទ្រព្យសកម្មមួយ ឬឯកតាបង្កើតសាច់ប្រាក់ មានចំនួនលើសពីតម្លៃដែលអាចប្រមូលមកបានវិញ ។ ការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត ។

#### (ញ) សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយវាមានលទ្ធភាពដែលតម្រូវឲ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងការបំពេញនូវកាតព្វកិច្ចនោះ ។ ប្រសិនបើផលប៉ះពាល់មានលក្ខណៈសារវន្ត សំវិធានធនត្រូវបានកំណត់ដោយអប្បហារលំហូរទឹកប្រាក់ដែលរំពឹងថានឹងត្រូវទូទាត់នាពេលអនាគត ដោយប្រើអត្រាមុនបង់ពន្ធដែលឆ្លុះបញ្ចាំងពីការប៉ាន់ស្មាននៃតម្លៃពេលវេលា ក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ ។ អប្បហារនៅសល់ ត្រូវបានទទួលស្គាល់ជាថ្លៃដើមហិរញ្ញវត្ថុ ។

#### (ដ) ប្រាក់កម្ចី និងបំណុលផ្សេងៗ

ប្រាក់កម្ចី និងបំណុលផ្សេងៗ ត្រូវបានគិតតាមរំលស់ថ្លៃដើមដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ។

# ឥណទានពលរដ្ឋរុងរឿង អិលធីឌី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

## 26. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ថ) ដើមទុន

ថ្លៃដើមកើនឡើងបណ្តាលមកពីការបោះប័ណ្ណភាគហ៊ុនធម្មតាទៅឲ្យអ្នកកាន់កាប់ហ៊ុន ត្រូវបានទទួលស្គាល់ជាការកាត់កងពីមូលធន ។

### (ទ) ទុនបម្រុងតាមបទបញ្ញត្តិ

ទុនបម្រុងតាមបទបញ្ញត្តិ ត្រូវបានបង្កើតឡើងសម្រាប់ភាពខុសគ្នារវាងសំវិធានធនលើឱនភាពឥណទានតាម ស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធុនតូចនិងមធ្យម និងសំវិធានធនតាមបទបញ្ញត្តិស្របតាមប្រកាស របស់ធនាគារជាតិនៃកម្ពុជាលេខ ធ7-017-344 ចុះថ្ងៃទី 1 ខែ ធ្នូ ឆ្នាំ 2017 និងសារាចរណែនាំលេខ ធ7-018-001 ស.រ.ឆ.ណ ចុះថ្ងៃទី 16 ខែ កុម្ភៈ ឆ្នាំ 2018 ស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើឱនភាពនៃតម្លៃសម្រាប់គ្រឹះស្ថានធនាគារនិងស្ថាប័នហិរញ្ញវត្ថុ ។

យោងតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា រាល់ឥណទានទាំងអស់របស់អតិថិជន ត្រូវធ្វើចំណាត់ថ្នាក់ទៅតាមសមត្ថភាពសងរបស់អ្នកខ្ចី និងចំនួនថ្ងៃដែលហួសកំណត់ដូចខាងក្រោម៖

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃដែលហួសកាលកំណត់សង | អត្រាសំវិធានធន |
|---|---|---|
| **ឥណទានរយៈពេលខ្លី (តិចជាង ឬស្មើមួយឆ្នាំ)៖** | | |
| ឥណទានធម្មតា/ស្តង់ដារ | <15 ថ្ងៃ | 1% |
| ឥណទានឃ្លាំមើល | 15 ថ្ងៃ ដល់ 30 ថ្ងៃ | 3% |
| ឥណទានក្រោមស្តង់ដារ | 31 ថ្ងៃ ដល់ 60 ថ្ងៃ | 20% |
| ឥណទានជាប់សង្ស័យ | 61 ថ្ងៃ ដល់ 90 ថ្ងៃ | 50% |
| ឥណទានបាត់បង់ | ≥ 91 ថ្ងៃ | 100% |
| **ឥណទានរយៈពេលវែង (ច្រើនជាងមួយឆ្នាំ)៖** | | |
| ឥណទានធម្មតា | < 30 ថ្ងៃ | 1% |
| ឥណទានឃ្លាំមើល | > 30ថ្ងៃ ដល់ 89 ថ្ងៃ | 3% |
| ឥណទានក្រោមស្តង់ដារ | ≥ 90ថ្ងៃ ដល់ 179 ថ្ងៃ | 20% |
| ឥណទានជាប់សង្ស័យ | ≥ 180ថ្ងៃ ដល់ 359 ថ្ងៃ | 50% |
| ឥណទានបាត់បង់ | 359 ថ្ងៃឬ ច្រើនជាងនេះ | 100% |

## 26. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ទ) ទុនបម្រុងតាមបទបញ្ញត្តិ (ត)

អនុលោមតាមប្រកាស 73 គ្រឹះស្ថានត្រូវប្រៀបធៀបសំវិធានធន ដែលគណនាតាមតម្រូវការខាងលើជាមួយនឹងសំវិធានធនដែលគណនាតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម៖

(i) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិទាបជាង នោះគ្រឹះស្ថានត្រូវកត់ត្រាសំវិធានធន ដែលត្រូវគណនាអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម និង

(ii) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិខ្ពស់ជាង នោះគ្រឹះស្ថានត្រូវកត់ត្រាសំវិធានធន ដែលត្រូវគណនាតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម និងផ្ទេរចំនួនលម្អៀងនោះពីប្រាក់ចំណេញរក្សាទុក ឬប្រាក់ខាតបង្គរទៅទុនបម្រុងតាមបទប្បញ្ញត្តិ នៅក្នុងមូលធននៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ។

## 27. ការពន្យល់អំពីការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធុនតូច និងមធ្យម

ដូចមានចែងក្នុងកំណត់សម្គាល់ 2 ទាំងនេះ គឺជារបាយការណ៍ហិរញ្ញវត្ថុដំបូងរបស់ក្រុមហ៊ុនដែលបានរៀបចំឡើងដោយអនុលោមតាម ស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធុនតូច និងមធ្យម ។

គោលនយោបាយគណនេយ្យដែលបានបង្ហាញនៅក្នុងកំណត់សម្គាល់ 26 ត្រូវបានអនុវត្តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 ព័ត៌មានប្រៀបធៀបដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 និងក្នុងការរៀបចំរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ដំបូងតាម ស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធុនតូច និងមធ្យម នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 (កាលបរិច្ឆេទផ្លាស់ប្តូររបស់ក្រុមហ៊ុន) ។

ក្នុងការរៀបចំរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដំបូង ដោយអនុលោមតាម ស.រ.ទ.ហ.អ.ក.ស សម្រាប់សហគ្រាសធុនតូច និងមធ្យម ក្រុមហ៊ុនបានធ្វើនិយ័តភាពទៅលើតួលេខដែលបានរាយការណ៍ពីមុននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដែលបានរៀបចំឡើងអនុលោមតាមស្តង់ដារគណនេយ្យកម្ពុជា និងតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ទាក់ទងនឹងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ (ហៅកាត់ថា "ស្តង់ដារពីមុន") ។

# ឥណទានពលរដ្ឋរុងរឿង អិលធីឌី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

## 27. ការពន្យល់អំពីការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធុនតូច និងមធ្យម (ត)

ការផ្ទៀងផ្ទាត់មូលធន

| | | ថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 | | | ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 | | |
|---|---|---|---|---|---|---|---|
| | កំណត់សម្គាល់ | ស្តង់ដារពីមុន ដុល្លារអាមេរិក | ផលប៉ះពាល់នៃការ ផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធុនតូច និងមធ្យម ដុល្លារអាមេរិក | ស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធុនតូច និងមធ្យម ដុល្លារអាមេរិក | ស្តង់ដារពីមុន ដុល្លារអាមេរិក | ផលប៉ះពាល់នៃការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធុនតូច និងមធ្យម ដុល្លារអាមេរិក | ស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធុនតូច និងមធ្យម ដុល្លារអាមេរិក |
| **ទ្រព្យសកម្ម** | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | គ | 106,956 | (106,956) | - | 71,790 | (71,790) | - |
| សមតុល្យជាមួយធនាគារជាតិ | គ | 156,193 | (156,193) | - | 157,028 | (157,028) | - |
| សាច់ប្រាក់ និង សាច់ប្រាក់សមមូល | គ | - | 1,160,761 | 1,160,761 | - | 996,618 | 996,618 |
| ប្រាក់បញ្ញើរជាមួយធនាគារនានា | ក(i) | 1,064,544 | (1,052,044) | 12,500 | 925,385 | (912,885) | 12,500 |
| ប្រាក់តម្កល់តាមច្បាប់ | គ | - | 154,432 | 154,432 | - | 154,432 | 154,432 |
| ឥណទានផ្តល់អោយអតិថិជន-សុទ្ធ | ក(i),(ii),គ | 8,774,571 | (439,909) | 8,334,662 | 6,286,935 | (506,444) | 5,780,491 |
| ទ្រព្យសកម្ម ផ្សេងៗ | ក(ii), គ | 253,569 | (190,269) | 63,300 | 190,416 | (90,896) | 99,520 |
| ទ្រព្យ និងបរិក្ខារ | | 72,987 | - | 72,987 | 45,655 | - | 45,655 |
| ទ្រព្យសកម្ម អរូបី | | 2,091 | - | 2,091 | 404 | - | 404 |
| ពន្ធពន្យារជាទ្រព្យសកម្ម-សុទ្ធ | ខ | 53,171 | 138,909 | 192,080 | 55,597 | 104,073 | 159,670 |
| ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំជាទ្រព្យសកម្ម | គ | 22,227 | (22,227) | - | 22,332 | (5,856) | 16,476 |
| សរុបទ្រព្យសកម្ម | | 10,506,309 | (513,496) | 9,992,813 | 7,755,542 | (489,776) | 7,265,766 |
| ទ្រព្យសកម្មសរុប (ពាន់រៀល-កំណត់សម្គាល់ 5) | | 42,413,969 | (2,072,983) | 40,340,986 | 31,161,768 | (1,967,920) | 29,193,848 |

# ឥណទានពលរដ្ឋរុងរឿង អិលធីឌី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

## 27. ការពន្យល់អំពីការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធុនតូច និងមធ្យម (ត)

ការផ្ទៀងផ្ទាត់មូលធន (ត)

| | | ថ្ងៃទី 1 ខែ មករា ឆ្នាំ 2018 | | | ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018 | | |
|---|---|---|---|---|---|---|---|
| | កំណត់សម្គាល់ | ស្តង់ដារពីមុន ដុល្លារអាមេរិក | ផលប៉ះពាល់នៃការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធុនតូចនិងមធ្យម ដុល្លារអាមេរិក | ស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធុនតូចនិងមធ្យម ដុល្លារអាមេរិក | ស្តង់ដារពីមុន ដុល្លារអាមេរិក | ផលប៉ះពាល់នៃការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធុនតូចនិងមធ្យម ដុល្លារអាមេរិក | ស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធុនតូចនិងមធ្យម ដុល្លារអាមេរិក |
| **បំណុល** | | | | | | | |
| ប្រាក់កម្ចី | ក(ii), គ | 3,188,755 | 54,557 | 3,243,312 | 583,335 | 2,157 | 585,492 |
| បំណុលផ្សេងៗ | ក(ii), គ | 126,022 | 95,806 | 221,828 | 70,119 | (55,431) | 14,688 |
| សំវិធានលើអត្ថប្រយោជន៍បុគ្គលិក | គ | 150,363 | (150,363) | - | - | - | - |
| បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | គ | 46,668 | (22,227) | 24,441 | 5,856 | (5,856) | - |
| សរុបបំណុល | | 3,511,808 | (22,227) | 3,489,581 | 659,310 | (59,130) | 600,180 |
| **មូលធន** | | | | | | | |
| ដើមទុន | | 3,088,645 | - | 3,088,645 | 3,088,645 | - | 3,088,645 |
| ប្រាក់ចំណេញរក្សាទុក | | 3,905,856 | (491,269) | 3,414,587 | 4,007,587 | (439,993) | 3,567,594 |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | ក(i) | - | - | - | - | 9,347 | 9,347 |
| សរុបមូលធន | | 6,994,501 | (491,269) | 6,503,232 | 7,096,232 | (430,646) | 6,665,586 |
| **សរុបបំណុលនិងមូលធន** | | 10,506,309 | (513,496) | 9,992,813 | 7,755,542 | (489,776) | 7,265,766 |
| **សរុបបំណុល និងមូលធន (ពាន់រៀល- កំណត់សម្គាល់ 5)** | | 42,413,969 | (2,072,983) | 40,340,986 | 31,161,768 | (1,967,920) | 29,193,848 |

## 27. ការពន្យល់អំពីការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធុនតូច និងមធ្យម (ត)

ការផ្ទៀតផ្ទាត់លទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែ ធ្នូ ឆ្នាំ2018៖

| | | 2018 | | |
|---|---|---|---|---|
| | កំណត់សម្គាល់ | ស្តង់ដារពីមុន ដុល្លារអាមេរិក | ផលប៉ះពាល់នៃការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធុនតូច និងមធ្យម ដុល្លារអាមេរិក | ស.រ.ទ.ហ.អ.ក. សម្រាប់សហគ្រាសធុនតូច និងមធ្យម ដុល្លារអាមេរិក |
| **ចំណូលប្រតិបត្តិការ** | | | | |
| ចំណូលការប្រាក់ | ក(ii),គ | 1,426,207 | 199,849 | 1,626,056 |
| ចំណាយការប្រាក់ | | (171,617) | - | (171,617) |
| ចំណូលពីការប្រាក់សុទ្ធ | | 1,254,590 | 199,849 | 1,454,439 |
| ចំណូលផ្សេងៗ | ក(ii) | 309,850 | (224,189) | 85,661 |
| **ចំណូលពីប្រតិបត្តិការសុទ្ធ** | | 1,564,440 | (24,340) | 1,540,100 |
| ចំណាយលើបុគ្គលិក | | (528,203) | - | (528,203) |
| រំលស់ | គ | (35,640) | (485) | (36,125) |
| ចំណាយប្រតិបត្តិការផ្សេងៗ | គ | (376,642) | 485 | (376,157) |
| សំវិធានធនឱនភាពនៃតម្លៃលើការខាតបង់ឥណទានផ្តល់ឲ្យអតិថិជន | ក(i) | (486,824) | 119,798 | (367,026) |
| **ប្រាក់ចំណេញមុនពេលដកពន្ធ** | | 137,131 | 95,458 | 232,589 |
| ចំណាយពន្ធលើប្រាក់ចំណេញ | | (35,400) | (34,835) | (70,235) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ/ លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | | 101,731 | 60,623 | 162,354 |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលធីឌី

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019

## 27. ការពន្យល់អំពីការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធុនតូច និងមធ្យម (ត)

### ក. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុល

*(i) ការរាយការណ៍ឡើងវិញនៃសំវិធានធនលើឱនភាពនៃតម្លៃ*

ក្រោមស្តង់ដារពីមុន ក្រុមហ៊ុនបានទទួលស្គាល់ការខាតបង់លើឱនភាពនៃតម្លៃ ឥណទានផ្តល់ដល់អតិថិជនផ្អែកលើថ្ងៃផុតកំណត់ ។ យោងតាមការអនុវត្ត ស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធុនតូច និងមធ្យម ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានធ្វើនិយ័តភាពដើម្បីបង្ហាញពីគំរូនៃការបាត់បង់កើតឡើង ។

| | ថ្ងៃទី 1 ខែ មករា ឆ្នាំ 2018<br>ដុល្លារអាមេរិក | ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018<br>ដុល្លារអាមេរិក |
|---|---|---|
| **របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ** | | |
| ការថយចុះនៃឥណទានផ្តល់ដល់អតិថិជន | (547,885) | (340,105) |
| ផលប៉ះពាល់នៃពន្ធដែលពាក់ព័ន្ធ | 109,577 | 68,021 |
| **និយ័តភាពលើប្រាក់ចំណេញរក្សាទុក** | (438,308) | (272,084) |
| **និយ័តភាពលើប្រាក់ចំណេញរក្សាទុក (ពាន់រៀល-កំណត់សម្គាល់ 5)** | (1,769,449) | (1,093,234) |

| | 2018<br>ដុល្លារអាមេរិក |
|---|---|
| **របាយការណ៍លទ្ធផលលម្អិតផ្សេងៗ** | |
| ការថយចុះនៃឱនភាពនៃតម្លៃលើឥណទានផ្តល់ដល់អតិថិជន | (119,798) |
| **និយ័តភាពប្រាក់ចំណេញមុនដកពន្ធ** | (119,798) |
| **និយ័តភាពប្រាក់ចំណេញមុនដកពន្ធ (ពាន់រៀល - កំណត់សម្គាល់ 5)** | (484,583) |

អនុវត្តតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា ក្រុមហ៊ុនបានធ្វើការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងតាមបទប្បញ្ញត្តិចំនួន 9,347 ដុល្លារអាមេរិក នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ2018 កំណត់សម្គាល់ 26(ទ) ។

## 27. ការពន្យល់អំពីការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធុនតូច និងមធ្យម (ត)

### ក. ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុល (ត)

### (ii) ការបង្ហាញឡើងវិញនូវរំលស់ថ្លៃដើម - ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុល ថ្លៃដើមប្រតិបត្តិការ និងការប្រាក់

ក្រោមស្តង់ដារពីមុន ថ្លៃដើមប្រតិបត្តិការ រួមបញ្ចូលទាំងកម្រៃ និងជើងសា ដែលជាផ្នែកនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ មិនត្រូវបានចាត់ចូលជាផ្នែកនៃការប្រាក់ប្រសិទ្ធភាព ហើយទទួលស្គាល់ជាចំណាយ នៅពេលប្រតិបត្តិការបានកើតមានឡើង ។ ការទទួលស្គាល់ចំណូលការប្រាក់ ត្រូវបានព្យួរនៅពេលដែលឥណទានក្លាយជាឥណទានមិនដំណើរការ ។

ក្រោម ស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធុនតូច និងមធ្យម ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងដំបូងដោយតម្លៃសមរម្យបូកនឹងថ្លៃចំណាយលើប្រតិបត្តិការ ដែលត្រូវបានបង្កឡើងដោយផ្ទាល់ទៅនឹងការទិញ ឬចេញផ្សាយ ហើយការវាស់វែងជាបន្តបន្ទាប់ត្រូវចំណាយរំលស់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព ។ ចំណូលកម្រៃ និងជើងសារ និងចំណាយបានភ្ជាប់ជាមួយអត្រាការប្រាក់សំខាន់ៗ ប្រកបដោយប្រសិទ្ធភាពលើទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានរាប់បញ្ចូលក្នុងការវាស់វែងអត្រាការប្រាក់ប្រសិទ្ធភាព ។

ផលប៉ះពាល់ដែលកើតឡើងពីការផ្លាស់ប្តូរត្រូវបានសង្ខេបដូចខាងក្រោម៖

| | ថ្ងៃទី 1 ខែ មករា ឆ្នាំ 2018<br>ដុល្លារអាមេរិក | ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018<br>ដុល្លារអាមេរិក |
|---|---|---|
| **របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ** | | |
| ការថយចុះនៃឥណទានផ្តល់ដល់អតិថិជន | (146,661) | (180,262) |
| ផលប៉ះពាល់នៃពន្ធដែលពាក់ព័ន្ធ | 29,332 | 36,052 |
| **និយ័តភាពលើប្រាក់ចំណេញរក្សាទុក** | (117,329) | (144,210) |
| **និយ័តភាពលើប្រាក់ចំណេញរក្សាទុក (ពាន់រៀល -កំណត់សម្គាល់ 5)** | (473,657) | (579,436) |

| | 2018<br>ដុល្លារអាមេរិក |
|---|---|
| **របាយការណ៍លទ្ធផលលម្អិតផ្សេងៗ** | |
| ការកើនឡើងពីចំណូលការប្រាក់ | 199,849 |
| ការថយចុះនៃចំណូលផ្សេងៗ | (224,189) |
| **និយ័តភាពលើប្រាក់ចំណេញមុនបង់ពន្ធ** | (24,340) |
| **និយ័តភាពលើប្រាក់ចំណេញមុនបង់ពន្ធ** (ពាន់រៀល -កំណត់សម្គាល់ 5) | (98,455) |

## 27. ការពន្យល់អំពីការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក សម្រាប់សហគ្រាសធុនតូច និងមធ្យម (ត)

### ខ. ពន្ធលើប្រាក់ចំណេញ

ការផ្លាស់ប្តូរខាងលើធ្វើឲ្យមានការកើនឡើងនៃពន្ធពន្យារជាទ្រព្យសកម្មដូចខាងក្រោម៖

| | ថ្ងៃទី 1 ខែ មករា ឆ្នាំ 2018<br>ដុល្លារអាមេរិក | ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2018<br>ដុល្លារអាមេរិក |
|---|---|---|
| សំវិធានធនការខាតបង់លើឱនភាពនៃតម្លៃ | (109,577) | (68,021) |
| ចំណូលពុំទាន់បានទទួលស្គាល់ | (29,332) | (36,052) |
| **ការកើនឡើងនៃពន្ធពន្យារជាទ្រព្យសកម្ម** | 138,909 | 104,073 |
| **ការកើនឡើងនៃពន្ធពន្យារជាទ្រព្យសកម្ម** (ពាន់រៀល - កំណត់សម្គាល់ 5) | 560,776 | 418,165 |

### គ. ការធ្វើចំណាត់ថ្នាក់ឡើងវិញ

បន្ថែមពីការធ្វើនិយ័តភាពខាងលើ ក្រុមហ៊ុនបានធ្វើចំណាត់ថ្នាក់ឡើងវិញយ៉ាងច្បាស់លាស់ ដើម្បីអនុលោមតាមការបង្ហាញនាការិយបរិច្ឆេទបច្ចុប្បន្ន ។

## 28. ព្រឹត្តិការណ៍ក្រោយរបាយការណ៍ហិរញ្ញវត្ថុ

### ផលប៉ះពាល់នៃការផ្ទុះឡើងនៃវីរុសកូរ៉ូណាដល់ក្រុមហ៊ុន

ចាប់តាំងពីខែ មករា ឆ្នាំ 2020 ការផ្ទុះឡើងនៃ Coronavirus ("COVID-19") មានផលប៉ះពាល់ដល់ស្ថានភាពពាណិជ្ជកម្មជាសកល និងប្រទេសកម្ពុជា ។ រហូតមកដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ COVID-19 មិនមានផលប៉ះពាល់ជាសារវន្តដល់ក្រុមហ៊ុនទេ ។ ដោយរង់ចាំមើលស្ថានភាពនៃការរីករាលដាលនៃ COVID-19 បន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍នេះ ការផ្លាស់ប្តូរនៃលក្ខខណ្ឌសេដ្ឋកិច្ចដែលអាចកើតឡើង អាចនឹងមានផលប៉ះពាល់ដល់លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ហើយទំហំនៃផលប៉ះពាល់មិនអាចប៉ាន់ស្មានបាននៅកាលបរិច្ឆេទនៃរបាយការណ៍នេះ ។ ក្រុមហ៊ុន នឹងបន្តការយកចិត្តទុកដាក់ទៅលើស្ថានភាពនៃ COVID-19 និងឆ្លើយតបយ៉ាងសកម្មចំពោះផលប៉ះពាល់របស់វាទៅលើស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលប្រតិបត្តិការរបស់ក្រុមហ៊ុន ។